មេរៀនទី ៥ បញ្ហាគ្រួសារ

គ្រូបង្រៀនថ្នាក់ថ្ងៃអាទិត្យម្នាក់បានព្យាយាមជួយ សិស្សដែលមានអាយុប្រាំបីឆ្នាំម្នាក់របស់នាង ឲ្យបានយល់ថា ឋានសួគ៌មានលក្ខណៈយ៉ាងដូចម្តេច។ នាងបានធ្វើការសន្និដ្ឋាន ដោយនិយាយថា "អ្នកគ្រូចូលចិត្តប្រៀបធៀបស្ថានសួគ៌ទៅនឹងផ្ទះ របស់អ្នកគ្រូ ដែលវាជាកន្លែងពោរពេញដោយសេចក្តីស្រឡាញ់ និងជាកន្លែងដែលអ្នកគ្រូអាចរកបានសន្តិភាព និង ទទួលស្គាល់។ ប្រាកដណាស់ ឋានសួគ៌ គឺដូចជានៅផ្ទះដែរ។

មានក្មេងប្រុសម្នាក់បានមើលទៅកាន់នាងទាំងបើកភ្នែកធំៗ ហើយឆ្លើយតបវិញថាៈ "ប្រសិនបើឋានសួគ៌ដូចជាផ្ទះរបស់ខ្ញុំមែន ខ្ញុំមិនចង់ទៅទីនោះទេ!"

គ្រួសារគឺជាព្រះតម្រិះរបស់ព្រះជាម្ចាស់តាំងពីមុនការបង្កើតពិភពលោកនេះទៅទៀត។ លំដាប់លំដោយនៅក្នុងសង្គម និង នៅក្នុងក្រុមជំនុំគឺយោងទៅតាមលំដាប់លំដោយនៅក្នុងគ្រួសារ។ ព្រះជាម្ចាស់បានប្រទានវិន័យយ៉ាងជាក់លាក់ សម្រាប់ទំនួលខុសត្រូវរបស់ប្តី របស់ប្រពន្ធ និង របស់កូនៗ។ នៅពេលដែលវិន័យត្រូវបានគេធ្វើតាម ក្រុមគ្រួសារក៏បានរឹងមាំ ហើយសមាជិកគ្រប់រូបត្រូវបានបំពេញឲ្យបរិបូរណ៌ និង សប្បាយរីករាយ។ ប៉ុន្តែនៅពេលដែលវិន័យទាំងនេះត្រូវបានគេមិនអើពើរ គ្រួសារប្រាកដជាមានបញ្ហា ហើយអាចនឹងត្រូវបែកបាក់គ្នាថែមទៀតផង។

នៅក្នុងប្រទេសជាច្រើននៅលើពិភពលោកសព្វថ្ងៃនេះ គ្រួសារជាច្រើនកំពុងតែមានបញ្ហាពិតប្រាកដមែន។ នៅប្រទេសខ្លះ ចំណងអាពាហ៍ពិពាហ៍ជាង ៥០ភាគរយ ត្រូវបានបញ្ចប់ដោយការលែងលះគ្នា។ នៅក្នុងប្រទេសផ្សេងទៀត តំណែងជាប្រពន្ធ ស្ទើរតែទាបជាងអ្នកបម្រើទៅទៀត។ កូនៗដែលធំពេញវ័យនៅក្នុងគ្រួសារដ៏ក្រៀមក្រំបែបនេះ គឺអាចនឹងបង្កើតក្រុមគ្រួសារប្រភេទដូចគ្នានោះដែរ នៅពេលដែលពួកគេរៀបការ។ តើមានបញ្ហាអ្វីខ្លះដែល បំផ្លាញក្រុមគ្រួសារ ហើយតើព្រះគម្ពីរបានថ្លែងយ៉ាងដូចម្តេចអំពីបញ្ហាទាំងនោះ? នោះគឺជាប្រធានបទរបស់យើងនៅក្នុងមេរៀនទី៥នេះ ។ ប្រសិនបើឋានសួគ៌ក៏ដូចជាផ្ទះយ៉ាងដូច្នោះដែរ តើអ្នកចង់ទៅទីនោះដែរឬទេ? យើងខ្ញុំសូមលើកទឹកចិត្តលោកអ្នកឲ្យធ្វើការអនុវត្ត ដោយផ្ទាល់ខ្លួនទៅតាមការគួរ នៅពេលដែលអ្នកធ្វើការសិក្សាមេរៀននេះ។

គម្រោងមេរៀន

ក) បញ្ហារវាងប្តី និង ប្រពន្ធ

ខ) បញ្ហារបស់កូនៗ

គ) ដំណោះស្រាយនៅក្នុងព្រះគម្ពីរសម្រាប់បញ្ហានៅក្នុងគ្រួសារ

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. ប្រាប់ពីគោលការណ៍ពីរយ៉ាងដែលនឹងជួយដោះស្រាយបញ្ហាបណ្តាលមកពី ភាពខុសគ្នាខាងឯវិញ្ញាណរវាងប្តី និង ប្រពន្ធ។

២. ស្គាល់ពីឥរិយាបថដែលនឹងជួយឲ្យប្តីប្រពន្ធដែលបានរៀបការហើយ ដោះស្រាយបញ្ហាតម្រូវការខាងផ្លូវភេទដែលខុសគ្នា បានយ៉ាងជោគជ័យ។

៣. ជ្រើសរើសយកការថ្លែងអំពីរបៀបដែលគ្រិស្តបរិស័ទគួរតែឆ្លើយតប នៅក្នុងករណីអំពើសហាយស្មន់ ដែលស្របជាមួយសេចក្តីបង្រៀនរបស់ព្រះគម្ពីរ។

៤. ប្រាប់ពីវិន័យទូទៅសម្រាប់ ការលែងលះគ្នាដែលយកទៅអនុវត្តជាមួយគ្រិស្តបរិស័ទ។

៥. ផ្សារភ្ជាប់ស្ថានភាពនៃបញ្ហាទៅនឹងដំណោះស្រាយត្រឹមត្រូវសម្រាប់បញ្ហានីមួយៗ។

៦. ជ្រើសរើសការថ្លែងដែល សង្ខេបយ៉ាងខ្លីៗអំពីឥរិយាបថដែលឪពុកម្តាយគួរតែមាន នៅក្នុងការបណ្តុះបណ្តាលកូនៗរបស់ពួកគេ។

៧. សង្ខេបនៅក្នុងតារាងមួយ អំពីឋានៈ និង ទំនួលខុសត្រូវរបស់សមាជិកម្នាក់ៗនៅក្នុងគ្រួសារ។

សកម្មភាពក្នុងការសិក្សា

១. សិក្សាតាមដំណើរវិវត្តនៃមេរៀន ដូចដែលអ្នកធ្លាប់ធ្វើ។ ត្រូវធ្វើឲ្យប្រាកដថា អ្នកបានអានខគម្ពីរទាំងប៉ុន្មានបានដាក់ឲ្យ និង បានចម្លើយសំណួរសិក្សានីមួយៗឲ្យរួចស្រេច មុនពេលបើកមើលចម្លើយដែលយើងបានផ្តល់ជូន។

២. បើកមើលនៅក្នុងអក្ខរានុក្រម សម្រាប់និយមន័យពាក្យសំខាន់ណាដែលអ្នកមិនទាន់បានស្គាល់។

៣. ធ្វើការប្រឡងផ្ទាល់ខ្លួន និង ផ្ទៀតផ្ទាត់ចម្លើយរបស់អ្នក។

ពាក្យសំខាន់

រ៉ៃយជំទង់	បង្គាប់	ប្ដីប្រពន្ធ
បន្ថោកតម្លៃ	បណ្ដោយតាម	រចនាសម្ព័ន្ធ
ភាពម៉ឺងម៉ាត់	ភាពធឹតក្បត់	ការចុះចូល
ជម្លោះ	ការបំបិទ	ជនរងគ្រោះ
រំខាន	រឹតបន្តឹង	ផ្ទឹម
បង្កកំហឹង		

ក) បញ្ហារវាងប្ដី និង ប្រពន្ធ

យើងមិនអាចរៀបរាប់ និងស្វែងរកដំណោះស្រាយសម្រាប់បញ្ហាទាំងអស់ ដែលមាននៅក្នុងគ្រួសារ នៅក្នុងមេរៀនដ៏ខ្លីនេះបានឡើយ។ នៅក្នុងការពិភាក្សារបស់យើងអំពីទំនាក់ទំនងសង្គម យើងបាន និយាយរួចហើយអំពី បញ្ហាជាច្រើនផ្នែកដែលអាចយកទៅអនុវត្តនៅក្នុងស្ថានភាពគ្រួសារផងដែរ។ យើង នឹងខំប្រឹង ពិភាក្សាបញ្ហាដែលមានជាពិសេសសម្រាប់គ្រួសារនៅក្នុងមេរៀននេះ ព្រមទាំងស្វែងរកគោល ការណ៍នៅក្នុងព្រះគម្ពីរដែលអាចផ្ដល់ការណែនាំសម្រាប់បញ្ហានីមួយៗ។ ដំបូង យើងនឹងចូលទៅមើលអំពី បញ្ហាធ្ងន់ធ្ងរ ខ្លះទៀតដែលអាចកើតឡើងរវាងប្ដី និង ប្រពន្ធ។

ភាពខុសគ្នាខាងវិញ្ញាណ

វត្ថុបំណងទី១. *ប្រាប់ពីគោលការណ៍ពីរយ៉ាងដែលនឹងជួយដោះស្រាយបញ្ហាបណ្ដាលមកពី ភាពខុសគ្នាខាងវិញ្ញាណរវាងប្ដី និង ប្រពន្ធ។*

បញ្ហាកើតឡើងនៅក្នុងចំណងអាពាហ៍ពិពាហ៍ ព្រោះមានដៃគូម្ខាងគឺជាគ្រិស្តបរិស័ទ ហើយម្ខាង ទៀតមិនមែនជាគ្រិស្តបរិស័ទ។ ជាច្រើនលើក គ្រិស្តបរិស័ទដែល បានរៀបការជាមួយនឹងអ្នកមិនជឿ គេ គិតថា ក្រោយពីពួកគេបានរៀបការហើយ គេនឹងអាចនាំ ប្ដីឬប្រពន្ធរបស់គេចូលទៅកាន់ព្រះអម្ចាស់បាន។ ប្រហែលជាប្ដី ឬ ប្រពន្ធ បានក្លាយជាគ្រិស្តបរិស័ទក្រោយពេលដែលពួកគេបានរៀបការហើយ ប៉ុន្តែដៃគូ ម្ខាងទៀតមិនផ្លាស់ប្រែចិត្តដែរនោះទេ។ បញ្ហាដែលកើតឡើងពីស្ថានភាពបែបនេះគឺ ធ្ងន់ធ្ងរណាស់៖ ដៃគូ ដែលជាគ្រិស្តបរិស័ទ ចង់បានអ្វីដែលជារបស់ព្រះជាម្ចាស់ ចង់ចូលរួមថ្វាយបង្គំនៅព្រះវិហារ និង អភិវឌ្ឍ ភាពពេញវ័យជាគ្រិស្តបរិស័ទ ស្របពេលដែលដៃគូមិនទាន់បានទទួលការ សង្គ្រោះ គឺត្រូវបានអូសទាញដោយការសប្បាយ និង ការចូលរួមជាមួយលោកីយ៍។ វាក៏មានការរំខាន ដល់ការចិញ្ចឹមបីបាច់ថែរក្សាកូនផងដែរ ហើយកូនៗប្រហែលជាមិនអាចទទួលយកព្រះគ្រិស្ត ជាព្រះអង្គ សង្គ្រោះរបស់ពួកគេផងដែរ ដោយសារតែមានគំរូពីឪពុកម្ដាយដែលមិនមែនជាគ្រិស្តបរិស័ទ។ មានពេល ខ្លះអ្នកមិនជឿក៏អូសទាញដៃគូដែលជាគ្រិស្តបរិស័ទ ឲ្យចេញឆ្ងាយពីជំនឿលើព្រះជាម្ចាស់ ហើយនាំចូល ទៅក្នុងអំពើបាប។

ប្រាកដណាស់ ដំណោះស្រាយដែលល្អបំផុតសម្រាប់បញ្ហានេះ ឬ បញ្ហាផ្សេងទៀត គឺត្រូវជៀសឲ្យ ផុតពីវា។ ការរៀបការជាមួយអ្នកមិនជឿត្រូវបានហាមប្រាម យោងទៅតាមគម្ពីរ២កូរិនថូស ៦:១៤-១៨៖

> សូមកុំសេពគប់ជាមួយអ្នកមិនជឿឡើយ។ តើសេចក្ដីសុចរិត និងសេចក្ដីទុច្ចរិតចូលរួមជាមួយគ្នា កើតឬទេ? តើពន្លឺ និងភាពងងឹត ចូលរួមជាមួយគ្នាកើតឬទេ? តើព្រះគ្រិស្ត* និងមារ*សាតាំងចុះ សំរុងគ្នាកើតឬទេ? តើអ្នកជឿ និងអ្នកមិនជឿមានទំនាក់ទំនងអ្វីនឹងគ្នា? តើព្រះវិហារ*របស់ព្រះជា ម្ចាស់ និងព្រះក្លែងក្លាយចូលគ្នាចុះឬទេ? យើងទាំងអស់គ្នាជាព្រះវិហាររបស់ព្រះជាម្ចាស់ដ៏មានព្រះ ជន្មរស់ ។

លំហាត់អនុវត្តន៍

១. តើចម្លើយមួយណានៅខាងក្រោមនេះ មួយណាដែលអ្នកគិតថា ជាចម្លើយល្អបំផុតសម្រាប់សំណួរដែលយើងទើបនឹងបានអាន។

ក) វាអាចមានការព្រមព្រៀងខ្លះៗសម្រាប់ឧទាហរណ៍នីមួយៗ។

ខ) វាមិនអាចមានការព្រមព្រៀងបាននោះទេ រវាងរឿងទាំងនេះ ព្រោះរឿងនីមួយមានតម្លៃផ្ទុយគ្នា។

គ) ដរាបណា មានការគោរពតាមបែបបទគ្នាទៅវិញទៅមក រឿងទាំងនេះអាចធ្វើការជាមួយគ្នាបាន។

ប្រាកដណាស់ ចម្លើយចំពោះសំណួរទាំងនេះគឺថា ត្រូវ និង ខុស ពន្លឺ និង ភាពងងឹត ព្រះគ្រិស្ត និង សាតាំង មិនអាចចុះសម្រុងគ្នា ឬ ធ្វើជាដៃគូគ្នាបានឡើយ។ អ្នកជឿម្នាក់ និង អ្នកមិនជឿម្នាក់គ្មានអ្វីដែលដូចគ្នា ក្រៅតែពីតម្រូវការមូលដ្ឋានជាមនុស្សតែប៉ុណ្ណោះ។ មនុស្សមានវ័យក្មេង គេចង់រៀបការខ្លាំងពេក គេសុខចិត្តមើលរំលងអ្វីជាដែលការបង្រៀនដ៏សំខាន់នៅក្នុងព្រះគម្ពីរ គឺការបើកទ្វារជីវិតរបស់គេទទួលជីវិតដែលខ្លោចចិត្ត និង ប្រកបដោយបញ្ហា។ ផ្លូវរបស់ព្រះជាម្ចាស់គឺ ជាផ្លូវដែលល្អបំផុត ហើយព្រះនឹងផ្គត់ផ្គង់គ្រប់តម្រូវការរបស់យើង ប្រសិនបើយើងនឹងស្តាប់បង្គាប់ទ្រង់។ យើងនឹងនិយាយអំពីរឿងនេះបន្ថែមទៀតនៅក្នុងមេរៀនបន្ទាប់ ដែលទាក់ទងនឹងការដោះស្រាយបញ្ហារបស់អ្នកដែលមិនទាន់រៀបការ។

សម្រាប់គ្រិស្តបរិស័ទដែលបានរៀបការជាមួយនឹងអ្នកមិនជឿហើយ ប្រហែលជាបានរៀបការតាំងពីមុនពេលដែលគាត់ក្លាយជាគ្រិស្តបរិស័ទទៅទៀត ។ លោកសាវ័កប៉ូលបានផ្តល់ការណែនាំពិសេសខ្លះៗនៅក្នុងគម្ពីរ១កូរិនថូស ៧:១២-១៦ ។ លោកប៉ូលបានលើកទឹកចិត្តគ្រិស្តបរិស័ទឲ្យបន្តជាមួយនឹងអាពាហ៍ពិពាហ៍នោះ ដរាបណា ដៃគូដែលមិនគោរពប្រណិបត្តិព្រះជាម្ចាស់នោះគឺសុខចិត្តនៅបន្តអាពាហ៍ពិពាហ៍នោះ។ គ្រិស្តបរិស័ទ មិនត្រូវជាម្នាក់ដែលចាក់ចេញនោះទេ។ សាជាថ្មីម្តងទៀត ព្រះជាម្ចាស់អាចប្រទាន ព្រះគុណ និងក្តីស្រឡាញ់ ដែលយើងត្រូវការ មាននរណាទៅដឹង? អ្នកមិនជឿ អាចត្រូវបានសង្គ្រោះនៅក្នុងពេលណាមួយ។ "បើគូស្រករដែលមិនជឿ ចាកចោលបងប្អូនដែលជាអ្នកជឿ អោយគេទៅចុះ បងប្អូនប្រុស ឬស្រីនោះគ្មានកំហុសអ្វីក្នុងរឿងនេះទេ។ ព្រះជាម្ចាស់បានត្រាស់ហៅយើងអោយមករស់ក្នុងសេចក្តីសុខសាន្ត" (គម្ពីរ១កូរិនថូស៧:១៥)។

លំហាត់អនុវត្តន៍

២ ហេតុអ្វីបានជាអ្នកគិតថាគ្រិស្តបរិស័ទត្រូវបានណែនាំឲ្យបន្តរស់នៅជាមួយអ្នកមិនជឿនៅក្នុងករណីមួយដែលយើងបានរៀបរាប់ខាងលើ? (សូមមើលគម្ពីរ ម៉ាថាយ ១៩:៤-៦)

....

នៅក្នុងគ្រួសារជាច្រើន ម្ដាយត្រូវតែទទួលទំនួលខុសត្រូវធ្វើជាអ្នកដឹកនាំខាងឯព្រលឹងវិញ្ញាណ។ នេះមិនមែនជាស្ថានភាពមួយដែលល្អនោះទេ ដ្បិតព្រះជាម្ចាស់បានបង្កើតប្ដីឲ្យធ្វើជាក្បាលរបស់គ្រួសារ ព្រមទាំងធ្វើជាអ្នកដឹកនាំខាងឯវិញ្ញាណផងដែរ។ កូនៗតែងតែមើលទៅកាន់គំរូឪពុករបស់គេ ហើយឪពុកមិនអាចរំពឹងថាគ្រួសាររបស់គេនឹងអាចមានកម្រិតខាងឯវិញ្ញាណខ្ពស់ជាងគាត់បាន
ឡើយ។

បញ្ហា ខាងឯវិញ្ញាណនៅក្នុងគ្រួសារអាចត្រូវបានដោះស្រាយដោយ ការស្ដាប់បង្គាប់តាមគោលការណ៍បទគម្ពីរតែប៉ុណ្ណោះ។ នៅក្នុងផ្នែកចុងក្រោយ នៃមេរៀននេះ យើងនឹងពិភាក្សាអំពីគោលការណ៍របស់គ្រិស្ដបរិស័ទសម្រាប់គ្រួសារ។ ប្រសិនបើអ្នកមានបញ្ហានៅក្នុងផ្នែកនេះនៃជីវិតគ្រួសាររបស់អ្នក អ្នកអាចផ្លាស់ប្ដូរវាបានដោយការយកគោលការណ៍ទាំងនេះទៅអនុវត្តនៅក្នុងជីវិតរបស់អ្នកផ្ទាល់។

លំហាត់អនុវត្តន៍

---

៣ យើងអាចត្រឹមតែពិភាក្សា អំពីគោលការណ៍មូលដ្ឋាន២យ៉ាងប៉ុណ្ណោះ ដែលនឹងជួយកែតម្រូវ ឬបញ្ចៀសភាពខុសគ្នាខាងឯវិញ្ញាណរវាងប្ដី និង ប្រពន្ធ ។ ចូរថ្លែងអំពីគោលការណ៍ដោយប្រើពាក្យរបស់អ្នកផ្ទាល់។

ក) ....

....

ខ) ....

....

តម្រូវការខុសគ្នាខាងឯផ្លូវភេទ

វត្ថុបំណងទី២. *ស្គាល់ពីឥរិយាបថដែលនឹងជួយឲ្យប្ដីប្រពន្ធដែលបានរៀបការហើយ ដោះស្រាយបញ្ហាតម្រូវការខាងផ្លូវភេទដែលខុសគ្នា បានយ៉ាងជោគជ័យ។*

ពេលខ្លះនៅក្នុងចំណងអាពាហ៍ពិពាហ៍ តម្រូវការទំនាក់ទំនងផ្លូវភេទរបស់ដៃគូម្នាក់ មានច្រើនជាងម្នាក់ទៀត។ ការបដិសេធ មិនឲ្យមានទំនាក់ទំនងផ្លូវភេទ គឺផ្ទុយនៅបទគម្ពីរ លើកលែងតែមានការព្រមព្រៀងគ្នាទៅវិញទៅមក (សូមមើលនៅក្នុងគម្ពីរ១កូរិនថូស៧:៥) និងក្នុងរយៈពេលខ្លីមួយតែប៉ុណ្ណោះ។ ប្ដី និង ប្រពន្ធដែលចង់ផ្គាប់តាមបំណងគ្នាទៅវិញទៅមក នឹងចុះចូលចំពោះគ្នាទៅវិញទៅមក ដោយយោងទៅតាមសេចក្ដីបង្រៀនក្នុងព្រះគម្ពីរ (សូមមើលគម្ពីរ១កូរិនថូស ៧:៣-៤)។ នៅក្នុងពេលជាមួយគ្នានោះដែរ ដៃគូទាំងសងខាងនឹងមានអារម្មណ៍ដឹងពីតម្រូវការផ្សេងទៀតរបស់ដៃគូ ចំពោះការសំដែងក្ដីស្រឡាញ់ និង មេត្រីភាព ដែលមិនផ្ដោតទៅលើតែទំនាក់ទំនងខាងផ្លូវភេទនោះទេ។

ជីវិតខាងផ្លូវភេទ នៅក្នុងអាពាហ៍ពិពាហ៍ នឹងត្រូវលើកយកទៅពិភាក្សាបន្ថែមទៀតឲ្យបានពេញលេញ នៅក្នុងមេរៀនទី៧។ ប្តីប្រពន្ធរៀបការរួច ដែលធ្វើតាមសេចក្តីបង្រៀនរបស់ព្រះគម្ពីរនៅក្នុងប្រការនេះ នឹងឃើញថា ការបំពេញខាងផ្លូវភេទ នៅក្នុងអាពាហ៍ពិពាហ៍ ជួយនាំឲ្យមានការរួបរួមគ្នា សម្រាប់បញ្ហាក្នុងផ្នែកផ្សេងៗទៀតដែរ។

លំហាត់អនុវត្តន៍

៤ តើឥរិយាបថមួយណា នៅខាងក្រោមនេះ ដែលអាចជួយប្តីប្រពន្ធដែលបានរៀបការរួច ដោះស្រាយបញ្ហានៃភាពខុសគ្នាក្នុងតម្រូវការខាងផ្លូវភេទបាន?

ក) ប្រពន្ធត្រូវតែចុះចូលជានិច្ច។

ខ) មានបំណងចង់បំពេញឲ្យគ្នាទៅវិញទៅមក។

គ) កាត់បន្ថយទំនាក់ទំនងផ្លូវភេទ ដោយការព្រមព្រៀងគ្នាទៅវិញទៅមក។

ភាពមិនស្មោះត្រង់

វត្ថុបំណងទី៣. *ជ្រើសរើសយកការថ្លែងអំពីរបៀបដែលគ្រិស្តបរិស័ទគួរតែឆ្លើយតប នៅក្នុងករណីអំពើសហាយស្មន់ ដែលស្របជាមួយសេចក្តីបង្រៀនរបស់ព្រះគម្ពីរ។*

បញ្ហាដែលប្រហែលជាការគំរាមកំហែងដល់អាពាហ៍ពិពាហ៍ខ្លាំងបំផុតគឺភាពមិនស្មោះត្រង់ (ការមិនស្មោះត្រង់រឿងផ្លូវភេទ ឬ អំពើសហាយស្មន់)។ បញ្ហានេះ នឹងត្រូវយកទៅពិភាក្សានៅក្នុងមេរៀនទី ៧។ អំពើសហាយស្មន់ គឺត្រូវបានហាមឃាត់ដាច់ខាត នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ និង សម្ព័ន្ធមេត្រីថ្មី ដូចដែលយើងបានឃើញនៅក្នុងមេរៀនទី២ យ៉ាងដូច្នោះដែរ។ នៅក្នុងមេរៀននេះ យើងចង់មើលទៅកាន់បញ្ហានេះតាមរយៈការយល់ឃើញរបស់ដៃគូដែលរងគ្រោះ ឬ ដែលត្រូវបានបំពាន។ តើអ្នកគួរឆ្លើយតបយ៉ាងដូចម្តេច ប្រសិនបើដៃគូរបស់អ្នកបានប្រព្រឹត្តអំពើសហាយស្មន់? តើអ្នកគួរតែសម្រេចចិត្ត លែងលះគ្នាភ្លាមៗ មែនឬទេ? តើអ្នកគួរតែបន្តចំណងអាពាហ៍ពិពាហ៍នោះទៀតទេ ប្រសិនបើការបំពាននោះនៅតែបន្តកើតឡើងម្តងហើយម្តងទៀតនោះ? នៅក្នុងបញ្ហានេះ មានបីផ្នែកដែលយើងចង់ធ្វើការពិចារណា៖

១. ប្រសិនបើ ប្តីប្រពន្ធដែលបានរៀបការហើយ នៅតែបន្តប្រព្រឹត្តអំពើសហាយស្មន់ តើអ្នកនៅតែមានតួនាទីបន្តរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍នោះទៀតដែរឬទេ? យោងទៅតាមព្រះបន្ទូលរបស់ព្រះយេស៊ូនៅក្នុងគម្ពីរ ម៉ាថាយ១៩:៩ ការលែងលះ គឺត្រូវបានអនុញ្ញាតឲ្យធ្វើ នៅក្នុងករណីមានអំពើសហាយស្មន់ ៖ "ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា បុរសណាលែងភរិយា(លើកលែងតែរួមរស់ជាមួយគ្នា ដោយឥតបានរៀបការ) ហើយទៅរៀបការនឹងស្ត្រីម្នាក់ទៀត បុរសនោះឯងជាអ្នកប្រព្រឹត្តអំពើផិតក្បត់"។ ដូច្នេះ ប្តី ឬប្រពន្ធ គឺគ្មានកាតព្វកិច្ចអ្វី នឹងត្រូវបន្តរស់នៅជាមួយនឹងដៃគូដែលគ្មាន ភាពស្មោះត្រង់។

២. ប្រសិនបើចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ដោយសារតែភាពមិនស្មោះត្រង់ តើភាគីដែលត្រូវបានគេបំពាន អាចរៀបការម្តងទៀតបានដែរឬទេ? អ្នកប្រាជ្ញព្រះគម្ពីរ មិនមានការយល់ស្រប គ្នា

លើការបកស្រាយបទគម្ពីរដែលទាក់ទងនឹងរឿងនេះឡើយ។ យោងទៅតាមអ្នកប្រាជ្ញខ្លះ ព្រះបន្ទូលរបស់ព្រះយេស៊ូនៅក្នុង គម្ពីរម៉ាថាយ១៩:៩ បានអនុញ្ញាតឲ្យរៀបការម្តងទៀតនៅក្នុងករណីនេះ។ ការបកស្រាយរបស់ពួកគេគឺថា នៅពេលដែលមនុស្សម្នាក់បានប្រព្រឹត្តអំពើសហាវស្មន់ គេបានរំលាយចំណងដែលធ្វើឲ្យគេជា "សាច់ឈាម" តែមួយជាមួយដៃគូរបស់គេហើយ។ ដូច្នេះ ដៃគូរបស់គេមិនជាប់នឹងចំណងនោះទៀតឡើយ។ ប្រសិនបើនេះជាការពិតមែន ភាគី ដែលត្រូវបានគេបំពាន់នោះ អាចមានសេរីភាពក្នុងការរៀបការជាមួយនឹងមនុស្សម្នាក់ទៀត ដែលមិនស្ថិតនៅក្នុងចំណងនៃអាពាហ៍ពិពាហ៍បាន។ការបកស្រាយមួយទៀតនោះគឺថា ការលែងលះគ្នា ត្រូវបានអនុញ្ញាតនៅក្នុងករណីមានអំពើសហាយស្មន់ ប៉ុន្តែមិនអនុញ្ញាតឲ្យមានការ រៀបការម្តងទៀតនោះទេ។ យើងនឹងពិភាក្សាចំណុចនេះបន្ថែមទៀត នៅក្នុងប្រធានបទ *ការលែង លះគ្នា*។

៣. មានរឿងជាច្រើនអាច ចូលរួមធ្វើឲ្យមានអំពើសហាយស្មន់បាន។ ដៃគូ ប្តីប្រពន្ធ ខ្លះអាចបដិសេធមិនព្រមមានទំនាក់ទំនងផ្លូវភេទជាមួយដៃគូរបស់ខ្លួន ដូច្នេះវាធ្វើឲ្យគាត់ត្រូវស្វែងរកនៅកន្លែងផ្សេងដើម្បីបំពេញតម្រូវការរបស់គាត់។ ឬមានពេលខ្លះ ដៃគូដែលមិនបានប្រុងប្រយ័ត្នខាងឯវិញ្ញាណរបស់ពួកគេ បានចុះចូលជាមួយនឹងការល្បួង។ ប្រាកដណាស់ ព្រះជាម្ចាស់មិនលើកលែងឲ្យអំពើណាមួយឡើយ ហើយអំពើទាំងពីរនោះសុទ្ធតែជាអំពើបាប។ ប៉ុន្តែ ឧបមាថា ភាគីដែលមិនស្មោះត្រង់នោះបានសារភាព និងពិតជាសោកស្តាយចំពោះអំពើបាបរបស់គេពិតមែន ហើយថែមទាំងសុំការអត់ទោសផងនោះ។ តើភាគីដែលត្រូវបានគេបំពាន គួរតែលើកលែងទោស និង ចាប់ផ្តើមចំណងទំនាក់ទំនងនោះសាជាថ្មីដែរឬទេ?

នេះប្រហែលជាកំហុស ពិបាកលើកលែងឲ្យខ្លាំងណាស់ សម្រាប់អ្នកណាដែលអាចនឹងឆ្លងកាត់នៅក្នុងជីវិតរបស់គេ។ ក្តីឈឺចាប់នៃ ទំនុកចិត្តដែលត្រូវបានគេបំផ្លាញ គឺវាចាក់ជ្រៅទៅក្នុងដួងចិត្តរបស់មនុស្សម្នាក់ ដែលធ្វើឲ្យគេពិបាកនឹងទុកចិត្តនរណាម្នាក់ម្តងទៀតណាស់ ប៉ុន្តែគោលការណ៍នៃការអត់ទោស គឺជាសេចក្តីបង្រៀនដ៏មានអំណាចនៅក្នុងបទគម្ពីរទាំងអស់។ ព្រះគ្រិស្តមិនត្រឹមតែបង្រៀនឲ្យមនុស្សចេះអត់ទោសនោះទេ (គម្ពីរម៉ាថាយ ៦:១៤) ប៉ុន្តែទ្រង់ក៏អត់ទោសឲ្យគេផងដែរ(គម្ពីរលូកា ៧:៤៧-៥០)។ ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យនឹងអំពើបាបនោះទេ ប៉ុន្តែទ្រង់ស្រឡាញ់មនុស្សមានបាបខ្លាំងណាស់ ដែលទ្រង់បានអនុញ្ញាត ឲ្យបុត្រាជាទីស្រឡាញ់របស់ទ្រង់រងរបួស រងការប្រមាថ និង ត្រូវបានគេឆ្កាង ដើម្បីឲ្យអំពើបាបរបស់យើងទទួលបានការអត់ទោស។ ព្រះគ្រិស្តបានអត់ទោសបាបឲ្យស្ត្រីម្នាក់ដែលត្រូវបានគេចាប់បានពេលកំពុងប្រព្រឹត្តអំពើសហាយស្មន់ (គម្ពីរយ៉ូហាន ៨:៣-១១) ។

តើមានក្តីស្រឡាញ់ណាទៀតដែលអាចបង្ហាញទៅកាន់ដៃគូរបស់ខ្លួន ក្រៅពីការផ្តល់នូវការអត់ទោសដូចដែលព្រះគ្រិស្តបានបង្ហាញសម្រាប់យើងនោះ? ប្រសិនបើអាចការពារចំណងអាពាហ៍ពិពាហ៍បាន និង គ្រួសារគ្រិស្តបរិស័ទត្រូវបានសង្គ្រោះ និង ប្រសិនបើប្តី និងប្រពន្ធអាចធ្វើការសន្យារបស់គេសាជាថ្មីម្តងទៀត ចំពោះគ្នាទៅវិញទៅមក និង ចំពោះព្រះជាម្ចាស់ផងនោះ ព្រះជាម្ចាស់នឹងប្រទានពរសម្រាប់អ្នកដែលអាចអត់ទោសនោះបាន។ នៅក្នុងករណីដូចនេះ ដៃគូទាំងសងខាងមិនគួរពិភាក្សាអំពីបញ្ហានោះសាជាថ្មីម្តងទៀត ជាមួយគ្នាទៅវិញទៅមក ឬ ជាមួយអ្នកផ្សេងទៀតទេ។ បញ្ហានោះត្រូវតែ អត់ទោស និង *បំភ្លេចចោល* តែមិនត្រូវភ្លេចអំណាចដែលអារក្សវាអាចនាំយើងឲ្យធ្វើអំពើបាបនោះទេ។

លំហាត់អនុវត្តន៍

៥ តើប្រយោគមួយណានៅខាងក្រោមនេះដែលបង្ហាញពីគោលការណ៍នៅក្នុងព្រះគម្ពីរដែល ទាក់ទងនឹងរបៀបដែលគ្រិស្តបរិស័ទគួរតែឆ្លើយតបទៅការប្រព្រឹត្តអំពើសហាយស្មន់របស់ដៃគូ។

ក) គ្រិស្តបរិស័ទត្រូវតែបន្តចំណងអាពាហ៍ពិពាហ៍ជាមួយដៃគូរបស់គេ នៅគ្រប់កាលៈទេសៈទាំងអស់។

ខ) ប្រសិនបើដៃគូម្ខាងប្រព្រឹត្តអំពើសហាយស្មន់ ដៃគូម្ខាងទៀតចាំបាច់ត្រូវចាក់ចេញ ហើយទៅរៀប ការជាមួយនឹងគ្រិស្តបរិស័ទម្នាក់ទៀត។

គ) ដៃគូប្តីប្រពន្ធ មានសេរីភាពអាចចាកចេញ ប្រសិនបើដៃគូម្ខាងទៀតបានប្រព្រឹត្តបាបក្នុងអំពើសហាយស្មន់។

ឃ) បាបនៃអំពើសហាយស្មន់ អាចនឹងត្រូវបានអត់ទោសឲ្យ ហើយចំណងអាពាហ៍ពិពាហ៍អាចបន្ត ទៅមុខទៀត។

៦ អ្នកប្រាជ្ញព្រះគម្ពីរខ្លះ បកស្រាយព្រះបន្ទូលរបស់ព្រះយេស៊ូនៅក្នុងគម្ពីរម៉ាថាយ ១៩:៩ ថាជាការអនុញ្ញាតឲ្យ

ក) ដៃគូដែលប្រព្រឹត្តអំពើសហាយស្មន់នោះអាច លែងលះ និងរៀបការម្តងទៀតបាន។

ខ) ដៃគូដែលរងគ្រោះ អាចលែងលះ និង រៀបការម្តងទៀតបាន។

គ) ដៃគូទាំងសងខាងអាចរៀបការម្តងទៀតបាន។

ការលែងលះ

វត្ថុបំណងទី ៤. *ប្រាប់ពីវិន័យទូទៅសម្រាប់ ការលែងលះគ្នាដែលយកទៅអនុវត្តជាមួយគ្រិស្តបរិស័ទ។*

បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ទាក់ទងនឹងការលែងលះគ្នានេះ គឺបានបង្ហាញយ៉ាងច្បាស់ៗនៅក្នុងគម្ពីរម៉ាឡាគីជំពូក២ ៖ "ព្រះអម្ចាស់ ជាព្រះនៃជនជាតិអ៊ីស្រាអែល មានព្រះបន្ទូលថា ព្រះអង្គមិនសព្វព្រះហឫទ័យ នឹងការលែងលះគ្នាទេ" ។

នៅក្នុងបទបន្ទូល ព្រះជាម្ចាស់ មានព្រះបន្ទូលប្រាប់ថា មូលហេតុមួយដែលទ្រង់សព្វព្រះហឫទ័យឲ្យប្តី និង ប្រពន្ធ មានភាពស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក គឺ ដើម្បីឲ្យកូនៗរបស់ពួកគេបានក្លាយជាមនុស្សរបស់ព្រះជាម្ចាស់ផងដែរ។ កូនៗរបស់គ្រិស្តបរិស័ទ ទទួលបានព្រះពរដ៏អស្ចារ្យជាច្រើន ដូចជាភាពនឹងនរ សីលធម៌ខ្ពស់ ក្តីស្រឡាញ់ មានទំនាក់ទំនងជាមួយនឹងឪពុកម្តាយ ការអធិស្ឋាន និង ការបង្រៀនព្រះគម្ពីរ។ មានបញ្ហាជាច្រើន ដែលអាចកើតឡើងទៅលើក្មេងដែលរងគ្រោះពីការលែងលះ។ ខ្ញុំស្គាល់គ្រូគង្វាលម្នាក់ដែលគាត់បានបង្រៀនជនល្មើសដែលជាក្មេងប្រុសចំនួន ៤០នាក់ ដែលត្រូវបានសមត្ថកិច្ចដាក់នៅក្នុងលំនៅដ្ឋានពិសេសមួយ ដោយសារតែពួកគេបានប្រព្រឹត្តបទល្មើសផ្សេងៗ។ លោកគ្រូគង្វាលនោះ ប្រាប់ខ្ញុំថា បទពិសោធន៍ដែលក្មេងទាំងអស់នោះ មានស្រដៀងគ្នា គឺថា ឪពុកម្តាយរបស់គេ

បានលែងលះគ្នា។ ពិតណាស់ មិនមែនក្មេងដែលមានឪពុកម្តាយលែងលះទាំងអស់សុទ្ធតែប្រព្រឹត្តបទល្មើសនោះទេ ប៉ុន្តែភាគច្រើនពួកគេរងគ្រោះតាមរបៀបណាមួយ។

វិន័យទូទៅសម្រាប់ការលែងលះ ៖

១. ការលែងលះត្រូវបានហាមជាដាច់ខាត (ហាមផ្តាច់) សម្រាប់គ្រិស្តបរិស័ទ (គម្ពីរ១កូរិនថូស ៧:១០-១១)

២. ត្រូវតែហាមជាដាច់ខាត ការរៀបការជាមួយមនុស្សដែលបានលែងលះហើយ (គម្ពីរលូកា ១៦:១៨; គម្ពីរម៉ាថាយ ៥:៣២; ១៩:៩ និង គម្ពីរ ១កូរិនថូស ៧:១១)

៣. អ្នកដែលបានលែងលះគ្នាហើយ មិនត្រូវរៀបការម្តងទៀតទេ (គម្ពីរ១កូរិនថូស ៧:១០-១១)។ នៅខាងដើមមេរៀននេះ យើងបានពិភាក្សាអំពីមូលហេតុមួយដែលអនុញ្ញាតឲ្យគ្រិស្តបរិស័ទអាចលែងលះគ្នា ហើយរៀបការម្តងទៀតបាន ប៉ុន្តែទោះជានៅក្នុងករណីនោះ ក៏នៅតែមានទុក្ខទោសដែលបំផ្លាញកូនៗ និង បំផ្លាញគំរូរបស់គ្រិស្តបរិស័ទផងដែរ។

នៅក្នុងករណី ដែលការលែងលះបានកើតមានឡើង ហើយគ្មានមធ្យោបាយអ្វីអាចផ្សះផ្សា ចំណងអាពាហ៍ពិពាហ៍នោះវិញទេ ដោយសារតែគូដៃម្ខាងបានរៀបការម្តងទៀតហើយ សហគមន៍គ្រិស្តបរិស័ទអាចជាប្រភពដែលអាចកំសាន្ត និង ជួយដល់ដៃគូម្ខាងដែលត្រូវបានគេលែងលះនោះ។ ព្រះជាម្ចាស់មិនដែលបែរព្រះភ័ក្ត្ររបស់ទ្រង់ចេញពីនរណាម្នាក់ដែលបានស្រែករកជំនួយពីទ្រង់នោះឡើយ ហើយទ្រង់នឹងប្រទានកម្លាំង ដើម្បីកសាងជីវិតជាថ្មី និង ដើម្បីប្រឈមមុខនឹងបញ្ហាដែលបានមកពីការលែងលះនោះ។ នៅក្នុងមេរៀនទី ៦ យើងនឹងមើលទៅលើចំណុចនេះ តាមការយល់ឃើញរបស់បុគ្គលដែលនៅតែឯងក្រោយពីមានការលែងលះ។

ខ្ញុំស្គាល់ប្តីប្រពន្ធមួយគូដែលធ្លាប់បានលែងលះប្តីប្រពន្ធរបស់ពួកគេរៀងខ្លួនពីមុនមកជាច្រើនឆ្នាំមកហើយ មុនពេលដែលពួកគេបានរៀបរាប់ការជាមួយគ្នា។ មិនយូរប៉ុន្មានក្រោយពេលរៀបការ ពួកគេទាំងពីរបានក្លាយជាគ្រិស្តបរិស័ទ។ បុរសជាប្តី បានគ្របដណ្តប់ដោយអារម្មណ៍ថាមានទោស ដោយសារតែគាត់គិតថា គាត់កំពុងរស់នៅក្នុងភាពសហាសស្មន់ជាមួយនឹងអាពាហ៍ពិពាហ៍លើកទីពីររបស់គាត់ តាំងពីពេលដែលគាត់បានលែងលះ ហើយរៀបការកន្លងមកនេះ។ លោកសាវ័កប៉ូលក៏បានផ្តល់ឲ្យនូវការណែនាំស្តីពីស្ថានភាពបែបនេះផងដែរ។

លំហាត់អនុវត្តន៍

---

៧ សូមអានគម្ពីរ១កូរិនថូស ៧:១៧-២៤។ តើខគម្ពីរនេះជាប់ទាក់ទងនឹងស្ថានភាពដែលយើងទើបបានរៀបរាប់ យ៉ាងដូចម្តេច?

....

....

៨ ដោយមិនចាំបាច់ ត្រឡប់ទៅមើលចំណុចមុន ចូរប្រាប់ពីវិន័យទូទៅសម្រាប់ការលែងលះ ដែលទាក់ទងនឹងគ្រិស្តបរិស័ទ។

....

....

បញ្ហាអាពាហ៍ពិពាហ៍ផ្សេងៗទៀត

វត្ថុបំណងទី៥. *ផ្សារភ្ជាប់ស្ថានភាពនៃបញ្ហាទៅនឹងដំណោះស្រាយត្រឹមត្រូវសម្រាប់បញ្ហានីមួយៗ។*

យើងនឹងនិយាយខ្លីៗអំពីបញ្ហាផ្សេងៗខ្លះទៀតដែលអាចធ្វើឲ្យមានការមិនសប្បាយចិត្ត និង ជម្លោះនៅក្នុងគ្រួសារ។

កង្វះការគោរពនិង ការទុកចិត្តគ្នាទៅវិញទៅមក

ខ្ញុំស្គាល់ប្ដីម្នាក់ដែលហាក់បីដូចជារីករាយ នឹងការមើលងាយប្រពន្ធរបស់គាត់នៅចំពោះមុខអ្នកដទៃ។ ខ្ញុំក៏ស្គាល់ ប្រពន្ធម្នាក់ដែលហាក់បីដូចជា ស្វែងរកតែឱកាសដើម្បីមើលងាយប្ដីរបស់នាង នៅក្នុងចំពោះមុខអ្នកដទៃ ដោយការជំទាស់ជាមួយគាត់ និង កែតម្រូវគ្រប់អ្វីដែលគាត់និយាយ។ ប្រហែលជាពួកគេប្រើប្រាស់វិធីសាស្ត្រនេះ ដើម្បីសងសឹក ចំពោះអាកប្បកិរិយាខ្លះរបស់ដៃគូខ្លួន ដូចជាខ្វះការបង្ហាញក្ដីស្រឡាញ់ ឬ ខ្វះការចុះចូល ប៉ុន្តែនេះមិនមែនជារបៀបរបស់គ្រិស្តបរិស័ទក្នុងការដោះស្រាយបញ្ហានៅក្នុងទំនាក់ទំនងនោះឡើយ។ គំរូនៅក្នុងព្រះគម្ពីរគឺថា ប្ដីត្រូវតែស្រឡាញ់ប្រពន្ធរបស់គាត់ ឲ្យស្មើនឹងក្ដីស្រឡាញ់ដែលព្រះគ្រិស្តស្រឡាញ់ក្រុមជំនុំដែរ (គម្ពីរអេភេសូ ៥:២៥-២៨) ហើយប្រពន្ធត្រូវតែលើកតម្កើង និង គោរពប្ដីរបស់នាង (គម្ពីរអេភេសូ ៥:៣៣)

ដៃគូទាំងសងខាងមិនត្រូវផ្ដល់ហេតុផលដែលធ្វើឲ្យដៃគូរបស់ខ្លួនប្រច័ណ្ឌនោះឡើយ។ ប្ដីប្រពន្ធគ្រិស្តបរិស័ទដែលមានបញ្ហានេះគួរតែពិភាក្សាគ្នា ដោយបើកចំហ និង ព្រមព្រៀងបញ្ចៀសរាល់ស្ថានភាពណាដែលអាចធ្វើឲ្យមានអារម្មណ៍ប្រច័ណ្ឌកើតមានឡើង។មនុស្សដែលប្រច័ណ្ឌ គ្រប់ពេលដោយគ្មានមូលហេតុអ្វីសោះ គេគួរតែទូលសូមឲ្យព្រះអម្ចាស់ជួយពួកគេ យកឈ្នះលើអារម្មណ៍បែបនោះ ហើយបង្កើតការទុកចិត្ត លើប្ដីប្រពន្ធរបស់ខ្លួន។

លំហាត់អនុវត្តន៍

៩ ការប្រច័ណ្ឌ កើតឡើងនៅពេលដែលខ្វះ:
ក) ការគោរព
ខ) ការចុះចូល
គ) ការប្ដេជ្ញាចិត្ត
ឃ) ការទុកចិត្ត

កង្វះទំនាក់ទំនង

អ្នកខ្លះនិយាយថា "ប្ដីរបស់ខ្ញុំមិនដែលនិយាយរកខ្ញុំសោះ" ។ នេះគឺជាការត្អូញត្អែររបស់ប្រពន្ធ ដែលប្រហែលជាបានចំណាយពេលវេលាពេញមួយថ្ងៃរបស់នាង មើលថែកូនៗតូច ហើយចង់មានទំនាក់ទំនងជាមួយប្ដីរបស់ពួកគេ នៅពេលល្ងាច។ ដើម្បីមានអាពាហ៍ពិពាហ៍ដ៏ល្អមួយ ត្រូវមានទំនាក់ទំនងដ៏ល្អមួយជាមុនសិន។ ប្ដីប្រពន្ធ គួរតែអាចចែករំលែកជាមួយគ្នាទៅវិញទៅមក បានច្រើនជាងនរណាទាំងអស់ ទាំងអំណរ និង ទុក្ខវេទនា ទាំងក្ដីសង្ឃឹម និង ក្ដីសុបិន ទាំងបញ្ហាធំ និង តូច ប្រចាំថ្ងៃរបស់ពួកគេ។

ការប្ដេជ្ញាជ្រុល

ចិត្តវិទ្យាដ៏ល្បីល្បាញម្នាក់ បានហៅបញ្ហានេះថាជា បញ្ហាលេខមួយនៅក្នុងគ្រួសាររបស់គ្រិស្តបរិស័ទជាច្រើន រួមទាំងគ្រូគង្វាលខ្លះ និង អ្នកដែលធ្វើការងារព័ន្ធកិច្ចពេញពេល។ វាពិតជាងាយស្រួលក្នុងការចូលរួមជាមួយនឹងសកម្មភាពជាច្រើន នៅក្រៅផ្ទះ ដែលធ្វើឲ្យគ្មានពេលវេលាសម្រាប់ជីវិតគ្រួសារ។ ផ្ទះក្លាយជា កន្លែងសម្រាប់គ្រាន់តែ បរិភោគអាហារ ងូតទឹក និង គេងប៉ុណ្ណោះ។ គ្រួសារមួយត្រូវបានទ្រុឌទ្រោម នៅពេលដែលឪពុករវល់តែរកលុយ និង ការងារព័ន្ធកិច្ចដើម្បីបំពេញតម្រូវការខាងឯវិញ្ញាណរបស់អ្នកដទៃ។ គាត់ផ្ដល់ខ្លួនគាត់ទាំងអស់សម្រាប់ការងារ ហើយទុកតែបន្តិចបន្តួច ឬគ្មានសោះសម្រាប់ប្រពន្ធ និងកូនៗរបស់គាត់។ ព្រះជាម្ចាស់សព្វព្រះទ័យឲ្យយើងប្រើប្រាស់ប្រាជ្ញាដែលទ្រង់បានប្រទានឲ្យ ទៅចាត់ចែងអាទិភាពត្រឹមត្រូវ នៅក្នុងជីវិតរបស់គាត់។ ប្រសិនបើប្ដី ចង់ក្លាយជាអ្នកដឹកនាំខាងឯវិញ្ញាណនៅក្នុងគ្រួសារ គាត់ត្រូវចំណាយពេល ជាមួយគ្រួសាររបស់គាត់តាមការប្រកបគ្នា និង ការបណ្ដុះបណ្ដាល។

លំហាត់អនុវត្តន៍

១០ សូមអានគម្ពីរ១ធីម៉ូថេ ៣:១-១២ ។ តើលោកប៉ុលបានធ្វើការណែនាំអ្វី ទាក់ទងអ្នកដឹកនាំក្រុមជំនុំ ដែលបញ្ជាក់ថាពួកគេត្រូវយកចិត្តទុកដាក់ផ្ដល់អាទិភាព ចំពោះគ្រួសាររបស់ពួកគេ?

....

....

បញ្ហាហិរញ្ញវត្ថុ

ប្ដីប្រពន្ធត្រូវតែធ្វើការជាមួយគ្នាដើម្បីបង្កើតជាកញ្ចប់ថវិកាមួយដែលអាចបំពេញតម្រូវការរបស់ពួកគេ និង ជួយគេមិនឲ្យមានបន្ទុកពីបំណុលដែលពិបាកនឹងសង។ គ្រឹះមូលដ្ឋានដែលល្អបំផុតគឺ ថ្វាយដប់ភាគរយដំបូងនៃចំណូលរបស់គ្រួសារទៅកាន់ព្រះអម្ចាស់ដោយភាពស្មោះត្រង់ ដោយយោងទៅតាមសេចក្ដីបង្រៀននៅក្នុងបទគម្ពីរ (គម្ពីរម៉ាឡាគី ៣:៨; គម្ពីរម៉ាថាយ ២៣:២៣)។ គ្រួសារជាច្រើនរងទុក្ខជាមួយនឹងបញ្ហាហិរញ្ញវត្ថុដែលមិនសមហេតុផល បញ្ហាជំងឺ និង ការចំណាយដោយឥតព្រៀងទុក ព្រោះតែពួកគេមិនមែនជាអ្នកដែលចូលចិត្តថ្វាយ ចំណែករបស់ព្រះជាម្ចាស់ដែលនៅក្នុងចំណូលរបស់គេនោះទេ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានបញ្ជាក់ម្ដងហើយម្ដងទៀត ពីគោលការណ៍នៃការថ្វាយ ។ យើងមិនអាច

ថ្វាយឲ្យលើសពីព្រះជាម្ចាស់បានទេ។ ទ្រង់បានសន្យាថា នឹងបំពេញតម្រូវការរបស់យើង នៅពេលដែល យើងស្មោះត្រង់ ជាមួយទ្រង់ (គម្ពីរកិច្ចការ ៦:៣៨)។

លោកសាវ័កប៉ូល បាននិយាយថា លោកបានរៀនឲ្យចេះស្កប់ចិត្ត មិនថាលោកមានច្រើនក្តី ឬតិច តួចក្តី (គម្ពីរភីលីព ៤:១១)។ ប្រាកដណាស់ ភាពសប្បាយរីករាយ មិនពឹងផ្អែកទៅលើទ្រព្យសម្បត្តិនោះ ទេ។ ព្រះជាម្ចាស់ មិនសព្វព្រះហឫទ័យឲ្យយើងព្រួយចិត្តអំពីការប្រមូលទ្រព្យនោះទេ ប៉ុន្តែទ្រង់សព្វព្រះទ័ យឲ្យយើងទុកចិត្តទ្រង់ ក្នុងការផ្គត់ផ្គង់សម្រាប់តម្រូវការប្រចាំថ្ងៃរបស់យើង។

ភាពខុសគ្នាក្នុងការបណ្តុះបណ្តាលកូន

មានបញ្ហាជាច្រើន ដែលអាចកើតឡើង ដោយសារតែឪពុកម្តាយមិនយល់ស្របគ្នាលើការបណ្តុះ បណ្តាល និងប្រៀនប្រដៅកូនៗរបស់ពួកគេ។ បញ្ហានេះអាចជៀសវាងបាន ដោយការធ្វើតាមគោល ការណ៍ចិញ្ចឹមអប់រំកូនដែលបានចែងនៅក្នុងព្រះគម្ពីរ។ យើងនឹងពិភាក្សាគ្នាអំពីគោលការណ៍ខ្លះ នៅក្នុង ចំណុចបន្ទាប់នៃមេរៀននេះ។ ឪពុកម្តាយគួរតែបង្ហាញពីការរួបរួមជានិច្ច នៅក្នុងការសម្រេចចិត្តណាមួយ ដែលទាក់ទងជាមួយនឹងកូនៗ ហើយពួកគេគួរតែពិភាក្សាអំពីភាពខុសគ្នាដោយសម្ងាត់ ដើម្បីកុំឲ្យកូនៗ របស់គេយកឱកាសដែលបានមកពីគំនិតផ្ទុយគ្នារបស់ពួកគេ ទៅបង្កើតជាបញ្ហាបន្ថែមទៀតរវាងឪពុក ម្តាយរបស់គេ។

បញ្ហាដែលទាក់ទងនឹងសាច់ញាតិ

នៅពេលបុរសម្នាក់ រៀបការ គាត់ត្រូវចាកចេញពីឪពុកម្តាយរបស់គាត់ ហើយទៅនៅជាមួយប្រពន្ធ របស់គាត់ (គម្ពីរម៉ាថាយ ១៩:៥) ។ បន្ទាប់មក ទំនួលខុសត្រូវរបស់គាត់គឺសម្រាប់ប្រពន្ធ និង កូនៗរបស់ គាត់ ហើយមិនអនុញ្ញាតឲ្យមានអ្វីផ្សេងមកបំផ្លាញការរួបរួមនៅក្នុងចំណងអាពាហ៍ពិពាហ៍របស់គាត់បាន ឡើយ។ ប៉ុន្តែព្រះគម្ពីរបាន បង្រៀនថា ប្រសិនបើមានសមាជិកគ្រួសារណា មានតម្រូវការចាំបាច់ យើងមិន ត្រូវបែរចេញពីអ្នកដែលត្រូវការនោះឡើយ។ គម្ពីរ១ធីម៉ូថេ ៥:៤-៨ បានបន្ថែមទំនួលខុសត្រូវរបស់អ្នកជឿ រួមបញ្ចូលទាំង តាយាយ បងប្អូន និង ស្ត្រីមេម៉ាយនៅក្នុងគ្រួសារផងដែរ។ នៅក្នុងខទី៨ បានបន្ថែមទៀត ថា ៖ "អ្នកណាមិនរវល់ថែទាំសាច់ញាតិរបស់ខ្លួន ជាពិសេស មិនថែទាំអ្នកដែលនៅក្នុងក្រុមគ្រួសាររបស់ ខ្លួនផ្ទាល់ អ្នកនោះបានក្បត់ជំនឿរបស់ខ្លួន ហើយអាក្រក់ជាងអ្នកមិនជឿទៅទៀត។"

លំហាត់អនុវត្តន៍

---

១១ ប្រសិនបើឪពុកម្តាយខាងប្តី ធ្វើការទាមទារដែលទាស់នឹងទំនួលខុសត្រូវរបស់គាត់សម្រាប់ ប្រពន្ធនិង កូនរបស់គាត់ តើមួយណាដែលតែងតែជាអាទិភាពទីមួយសម្រាប់គាត់?

ក) ឪពុកម្តាយ

ខ) ប្រពន្ធ និង កូន

១២ ចូរផ្គូផ្គង បញ្ហានៅក្នុងអាពាហ៍ពិពាហ៍(ជួរខាងស្តាំ) ទៅនឹងដំណោះស្រាយដែលត្រឹមត្រូវ (ជួរខាងឆ្វេង) ។ ចូរសរសេរលេខនៃបញ្ហានីមួយៗនៅខាងមុខដំណោះស្រាយដែលអ្នកបាន ជ្រើសរើសសម្រាប់វា។

.........ក) កញ្ចាប់ថវិកាមួយដែលផ្តល់អាទិភាពឲ្យ ចំណែករបស់ព្រះជាម្ចាស់។

.........ខ) ដើរតាមគំរូរបស់ព្រះគម្ពីរ ដោយស្រឡាញ់ និង គោរពគ្នាទៅវិញទៅមក។

.........គ) ទុកចិត្តគ្នាទៅវិញទៅមក ព្រមទាំងធ្វើខ្លួន ជាមនុស្សគួរឲ្យទុកចិត្តដែរ។

.........ឃ) ចំណាយពេលវេលា ឲ្យបានច្រើនជាមួយ គ្រួសារ។

.........ង) ធ្វើតាមគោលការណ៍របស់គ្រិស្តបរិស័ទ ហើយបង្ហាញពីការរួបរួម។

.........ច) អាទិភាពទីមួយរបស់មនុស្សប្រុស គឺ តម្រូវការគ្រួសារផ្ទាល់ខ្លួនរបស់គាត់ បន្ទាប់ មកទើបជាតម្រូវការចាំបាច់របស់សមាជិក គ្រួសារដទៃផ្សេងទៀត។

..........ឆ) ចែករំលែកជាមួយគ្នាទៅវិញទៅមក។

១) ការប្តេជ្ញាជ្រុល
២) បញ្ហាទាក់ទងនឹងសាច់ញាត្តិ
៣) បញ្ហាហិរញ្ញវត្ថុ
៤) កង្វះការគោរព
៥) ភាពខុសគ្នាក្នុងការ បណ្តុះបណ្តាលកូន
៦) កង្វះទំនាក់ទំនង
៧) ការប្រច័ណ្ឌ

ខ) បញ្ហារបស់កូនៗ

វត្ថុបំណងទី៦. *ជ្រើសរើសការថ្លែងដែល សង្ខេបយ៉ាងខ្លីៗអំពីឥរិយាបថដែលឪពុកម្តាយគួរតែមាន នៅក្នុងការបណ្តុះបណ្តាលកូនៗរបស់ពួកគេ។*

ការមិនស្តាប់បង្គាប់

ការមិនស្តាប់បង្គាប់ឪពុកម្តាយ គឺជាសញ្ញាបញ្ជាក់ថ្ងៃចុងក្រោយ។ ក្រឹត្យវិន័យតែមួយគត់ ដែលរួម ជាមួយនឹងការសន្យាផងនោះ គឺថា៖ "ចូរគោរពមាតាបិតារបស់អ្នក ដើម្បីអោយអ្នកមានអាយុយឺនយូរ នៅ លើដីដែលព្រះអម្ចាស់ជាព្រះនៃអ្នក ប្រទានដល់អ្នក" (គម្ពីរនិក្ខមនំ ២០:១២) ។ កូនៗត្រូវរៀនស្តាប់បង្គាប់ តាមរយៈការបណ្តុះបណ្តាល និង ការប្រៀនប្រដៅយ៉ាងយកចិត្តទុកដាក់ ពីឪពុកម្តាយរបស់ពួកគេ៖ "ចូរ អប់រំកូនក្មេងអោយមានទំលាប់ល្អតាំងពីតូច គេនឹងរក្សាទំលាប់នេះរហូតដល់ចាស់" (គម្ពីរសុភាសិត ២២: ៦) ។ ការបណ្តុះបណ្តាលមិនកើតឡើងឯងៗ នោះទេ វាទាមទារឲ្យមានការប្តេជ្ញាចិត្ត និង ការស្មោះត្រង់ចិត្ត គ្រប់គ្រងលើស្ថានការណ៍នោះផងដែរ ៖ "រីឯក្មេងដែលគេបណ្តោយអោយធ្វើអ្វីតាមចិត្ត តែងតែបំបាក់មុខ ម្តាយ" (គម្ពីរសុភាសិត ២៩:១៥)។ ឪពុកម្តាយមិនត្រូវអនុញ្ញាតឲ្យកូនមិនស្តាប់បង្គាប់គាត់ តាំងពីនៅតូច នោះទេ ប្រសិនបើគាត់ចង់គ្រប់គ្រងកូនបាននៅពេលវាធំឡើង។

បច្ចុប្បន្ននេះ ឪពុកម្ដាយជាច្រើនមានអារម្មណ៍ក្រៀមក្រំ ដោយសារតែការបះបោរ របស់កូនៗដែលមានវ័យជំទង់របស់គាត់។ បន្ថែមពីលើ នេះទៀត គឺមានសេចក្ដីល្បួងមកលើយុវជន ឲ្យសាកល្បងសេពគ្រឿងញៀន ឬ គ្រឿងស្រវឹង ឬ សាកល្បងជាមួយនឹងការរួមភេទ។ ក្រុមជំនុំ ក៏ទទួលផលប៉ះពាល់ពីបន្ទុកដែលក្រុមគ្រួសារបានរងនេះដែរ ព្រោះមានកូនស្រីដែលមិនទាន់រៀបការ មានផ្ទៃពោះ ឬ មានកូនប្រុសក្លាយជាអ្នកញៀនថ្នាំ ឬ កូនប្រុសឬកូនស្រី បានចាកចេញពីគ្រួសារហើយទៅស្វែងរកការសប្បាយតាមរបៀបមិនបរិសុទ្ធ។

ប្រសិនបើគ្រួសាររបស់អ្នកទទួលរងគ្រោះដោយសារតែបញ្ហាបែបនេះដែរ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យពង្រឹងជំនឿរបស់អ្នក ហើយមិនត្រូវចុះចាញ់ឡើយ។ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ចំពោះអ្នក ហើយទ្រង់ស្រឡាញ់កូនដ៏រឹងចចេសរបស់អ្នកដែរ។ សូមទទួលការលើកទឹកចិត្តពីក្នុងរឿងកូនពៅដែលបាត់ហើយរកឃើញវិញ នៅក្នុងគម្ពីរលូកា ១៥:១១-៣២។

ឪពុកដែលនៅក្នុងរឿងនេះ មិនបានព្យាយាមហាមឃាត់មិនឲ្យកូនប្រុសរបស់គាត់ចាកចេញពីផ្ទះនោះទេ ប៉ុន្តែនៅក្នុងចិត្តរបស់គាត់ពិតជាដោយភាពក្រៀមក្រំនៅពេលដែលឃើញកូនប្រុសរបស់គាត់ចាកចេញទៅ។ ខ្ញុំជឿថា គាត់ក៏បានអធិស្ឋានសម្រាប់កូនប្រុសរបស់គាត់ទាំងថ្ងៃទាំងយប់ និងមិនដែលឈប់រំពឹងក្នុងចិត្តថាព្រះជាម្ចាស់នឹងធ្វើការល្អសម្រាប់កូនរបស់គាត់ក្នុងស្ថានភាពមួយនេះដែរ។ តើអ្នកគិតថាគាត់បានចេញទៅតាមផ្លូវស្វែងរកកូនរបស់គាត់ប៉ុន្មានដងក្នុងមួយថ្ងៃ? ព្រះគម្ពីរបានចែងថា កូនប្រុសរបស់គាត់បានសម្រេចចិត្តត្រឡប់មកផ្ទះវិញ ក្រោយពេលគេបានចំណាយប្រាក់របស់គេ និង បាត់បង់អ្វីៗគ្រប់បែបយ៉ាងដែលគេមាន " លុះគិតដូច្នោះហើយ កូនពៅក៏វិលត្រឡប់ទៅរកឪពុកវិញ។ កាលឪពុកឃើញកូនពីចម្ងាយ គាត់មានចិត្តអាណិតអាសូរក្រៃលែងក៏រត់ទៅទទួលកូន ហើយឱបថើបទៀតផង។" (ខ២០)។

អ្នកអាចទទួលយកសេចក្ដីសន្យានៅក្នុងគម្ពីរសុភាសិត ២២:៦។ មានពេលខ្លះ អ្វីដែលអ្នកអាចធ្វើបានគឺ ថ្វាយកូនរបស់អ្នកដែលមានបញ្ហានោះទៅកាន់ព្រះអម្ចាស់ ហើយទុកចិត្តថាទ្រង់នឹងធ្វើឲ្យការល្អកើតមានឡើង ប៉ុន្តែត្រូវត្រៀមខ្លួនជានិច្ចដើម្បីជួយកូនរបស់អ្នកដោះស្រាយបញ្ហា នៅពេលដែលគេបែរមករកអ្នកដើម្បីជួយគេផងដែរ។ ដូចជាព្រះវរបិតានៃស្ថានបរមសុខ ទ្រង់ទទួលមនុស្សមានបាបដែលបានលន់តួ មិនខ្វល់ថាគេបានធ្វើអ្វី ឪពុកម្ដាយជាគ្រិស្តបរិស័ទត្រូវបង្ហាញក្ដីស្រលាញ់ និង ចិត្តអាណិតអាសូរទៅកាន់កូនៗរបស់គេដែលបានបះបោរ នៅពេលណាដែលពួកគេស្រែករកជំនួយដូចគ្នាដែរ។

កង្វះ ការបណ្ដុះបណ្ដាល និង ការប្រៀនប្រដៅ

ជារឿយៗ ទាំងឪពុកទាំងម្ដាយ ធ្វើការនៅក្រៅផ្ទះ ហើយពួកគេមានកម្លាំងថាមពលតែបន្តិចបន្តួចប៉ុណ្ណោះសម្រាប់ទំនួលខុសត្រូវយ៉ាងសំខាន់ក្នុងការបណ្ដុះបណ្ដាល និង ប្រៀនប្រដៅកូនៗរបស់ពួកគេ។ ពួកគេតែងតែរំពឹងឲ្យ ក្រុមជំនុំ និង សាលារៀនបំពេញតួនាទីទាំងនេះ ដែលព្រះជាម្ចាស់បានប្រទានឲ្យពួកគេធ្វើទៅវិញ។ ការបណ្ដុះបណ្ដាលកូនជាកិច្ចការលំបាកណាស់។ យើងមិនអាច បណ្ដុះបណ្ដាលកូនដោយគ្រាន់តែប្រាប់ ពួកគេថាគួររស់របៀបណានោះទេ។ អ្នកត្រូវតែធ្វើកិច្ចការជាមួយពួកគេ ដើម្បីកែតម្រូវកំហុសគ្រប់បែបយ៉ាង ដើម្បីបង្ហាញពួកគេពីអ្វីដែលត្រូវ និង អ្វីដែលខុស ដើម្បីបង្រៀនពួកគេពីអ្វីដែលព្រះ

បន្ទូលរបស់ព្រះជាម្ចាស់បានចែង។ ការបណ្តុះបណ្តាលកូនគឺជាសកម្មភាពដែលត្រូវតែបន្តធ្វើ រហូតដល់ពេលដែលកូនៗបានពេញវ័យគ្រប់គ្រាន់ដើម្បីចាកចេញពីផ្ទះ និង ទទួលយកទំនួលខុសត្រូវជាមនុស្សពេញវ័យម្នាក់។

កង្វះសេចក្តីស្រឡាញ់ និង ការយល់ដឹង

មនុស្សគ្រប់គ្នាត្រូវការក្តីស្រឡាញ់ និង ការថ្នាក់ថ្នម។ កូនៗដែលធំលូតលាស់នៅក្នុងគ្រួសារដែលមិនសូវមានការបង្ហាញក្តីស្រឡាញ់ ក៏មានការលំបាកក្នុងការបង្ហាញក្តីស្រឡាញ់ទៅចំពោះអ្នកដទៃដែរ។ ឪពុកម្តាយគួរញែកពេលវេលាឲ្យបានច្រើនដើម្បីធ្វើការបង្ហាញក្តីស្រឡាញ់ទៅកាន់កូនៗរបស់ពួកគេ។

ឪពុកម្តាយខ្វះការយល់ដឹង នៅពេលដែលពួកគេទាមទាររឿងជាច្រើនពីកូនៗរបស់ពួកគេ ឬ នៅពេលដែលពួកគេ បណ្តោយតាម ឬ មិនហាមឃាត់កូន ហើយតែងតែអនុញ្ញាតឲ្យកូនៗរបស់ពួកគេធ្វើតាមអំពើចិត្ត។ រឿងដែលជ្រុលហួសកម្រិតទាំងពីរនេះ អាចបង្កឲ្យមានបញ្ហាបាន។ កូនៗដែលទទួលការរិះគន់ និង ការចំអកច្រើន នឹងមានអារម្មណ៍ថាតូចទាបជាងគេ និង គ្មានទំនុកចិត្ត ដែលនឹងនៅជាមួយពួកគេរហូតដល់ពួកគេធំពេញវ័យ។ មធ្យោបាយវិជ្ជមាន ក្នុងការបណ្តុះបណ្តាល
កូនៗ នឹងជួយបញ្ចៀសរាល់បញ្ហាទាំងនេះ។

មនុស្សគ្រប់គ្នាឆ្លើយតបបានយ៉ាងល្អ ទៅចំពោះការយល់ស្រប។ ការកែតម្រូវ ចំពោះការធ្វើខុស គួរតែធ្វើឲ្យស្មើគ្នាជាមួយនឹងការសរសើរ ចំពោះការធ្វើអ្វីដែលត្រឹមត្រូវ។ វិន័យសម្រាប់ក្តីស្រឡាញ់ដែលយើងបានរៀននៅក្នុងមេរៀនទី២ (គម្ពីរ១កូរិនថូសជំពូក ១៣) គួរតែយកមកអនុវត្តនៅក្នុងឥរិយាបថរបស់ឪពុកម្តាយ និង នៅក្នុងទង្វើដែលធ្វើទៅលើកូនៗ ព្រមទាំងទៅលើទំនាក់ទំនងដទៃទៀតដែរ។ មនុស្សគ្រប់គ្នាមានសិទ្ធិទទួលបានភាពថ្លៃថ្នូរ និង ការគោរព ដោយមិនគិតពីអាយុនោះទេ។

លំហាត់អនុវត្តន៍

---

១៣ តើប្រយោគមួយណា នៅខាងក្រោមនេះ ដែលនិយាយសង្ខេបបានល្អជាងគេ ពីរបៀបដែលឪពុកម្តាយគួរតែឆ្លើយតបទៅនឹងបញ្ហារបស់កូនៗដែលមិនស្តាប់បង្គាប់ កង្វះការបណ្តុះបណ្តាល និង បញ្ហាកង្វះក្តីស្រឡាញ់។

ក) ឪពុកម្តាយមិនគួរអនុញ្ញាតឲ្យមានការមិនស្តាប់បង្គាប់ទេ ប៉ុន្តែគួរតែយកចិត្តទុកដាក់បណ្តុះបណ្តាលកូនៗរបស់ពួកគេ និង បង្ហាញថាអ្នកស្រឡាញ់ពួកគេ ។

ខ) រឿងសំខាន់បំផុតដែលឪពុកម្តាយធ្វើបានសម្រាប់កូនៗរបស់ពួកគេគឺ ការដាក់ទោសពួកគេនៅពេលដែលពួកគេមិនស្តាប់បង្គាប់។

គ) ដំណោះស្រាយនៅក្នុងព្រះគម្ពីរសម្រាប់បញ្ហានៅក្នុងគ្រួសារ

វត្ថុបំណងទី៧. *សង្ខេបនៅក្នុងតារាងមួយ អំពីឋានៈ និង ទំនួលខុសត្រូវរបស់សមាជិកម្នាក់នៅក្នុងគ្រួសារ។*

នៅចុងបញ្ចប់នៃមេរៀននេះ ខ្ញុំចង់សង្ខេបយ៉ាងខ្លីអំពី គោលការណ៍មូលដ្ឋាននៅក្នុងព្រះគម្ពីរ ដែលទាក់ទងនឹង ទំនួលខុសត្រូវរបស់ប្ដី របស់ប្រពន្ធ របស់ឪពុកម្ដាយ និង របស់កូនៗ។ ការធ្វើតាមគោលការណ៍ទាំងនេះ នឹងជួយអ្នកដោះស្រាយបញ្ហាជាច្រើន ដែលកើតឡើងនៅក្នុងគ្រួសារ។ គោលការណ៍ទាំងនោះគឺជាគំរូរបស់ព្រះជាម្ចាស់សម្រាប់គ្រួសារគ្រិស្តបរិស័ទដែលជោគជ័យនៅក្នុងជីវិត។

ទំនួលខុសត្រូវរបស់ប្ដី

ផ្ដល់ការដឹកនាំ

គំរូដែលនៅក្នុងព្រះគម្ពីរគឺថា ប្ដីទទួលបានការដឹកនាំពីព្រះអម្ចាស់សម្រាប់គ្រួសាររបស់គាត់។ ព្រះជាម្ចាស់ដឹកនាំលោក អប្រាហាំឲ្យចាកចេញពីផ្ទះរបស់លោក ហើយចូលទៅទឹកដីដែលព្រះជាម្ចាស់បានជ្រើសរើស (គម្ពីរលោកុប្បត្តិ ១២:១) ។ ព្រះអម្ចាស់បានដឹកនាំលោកយ៉ាកុប ឲ្យត្រឡប់ទៅទឹកដីរបស់ឪពុកលោកវិញ (គម្ពីរលោកុប្បត្តិ ៣១:៣) ។ ព្រះជាម្ចាស់បានដឹកនាំលោកយ៉ូសែប ឲ្យរត់ទៅស្រុបអេស៊ីព្ទដើម្បីគ្រួសាររបស់លោក(គម្ពីរម៉ាថាយ ២:១៣)។

ព្រះវិញ្ញាណដ៏វិសុទ្ធ បានដឹកនាំលោកប៉ូលឲ្យបកស្រាយពីក្រិតក្រមនៃសិទ្ធិអំណាច នៅក្នុងគ្រួសាររបស់គ្រិស្តបរិស័ទ៖ "ក៏ប៉ុន្តែ ខ្ញុំចង់អោយបងប្អូនជ្រាបថា ព្រះគ្រិស្តនាំមុខ បុរសគ្រប់រូប បុរសនាំមុខស្ត្រី ហើយព្រះជាម្ចាស់នាំមុខព្រះគ្រិស្ត។" (គម្ពីរ១កូរិនថូស ១១:៣)។ " កុមារាកុមារីអើយ ចូរស្ដាប់បង្គាប់មាតាបិតា ដោយយល់ដល់ព្រះអម្ចាស់ ធ្វើដូច្នេះទើបត្រឹមត្រូវ។" (គម្ពីរអេភេសូ ៦:១) ។

ដូចជាក្បាលដែលត្រូវដឹងគ្រប់យ៉ាងពីខ្លួនប្រាណទាំងមូល មុនពេលវាអាចមានទំនាក់ទំនងអំពីទិសដៅបាន ប្ដីក៏ត្រូវដឹងគ្រប់តម្រូវការប្រពន្ធ និង កូនៗរបស់គាត់ ព្រមទាំងទិសដៅដែលមកពីព្រះជាម្ចាស់ ដើម្បីធ្វើខ្លួនជាអ្នកដឹកនាំខាងឯវិញ្ញាណនៅក្នុងគ្រួសារមួយបានផងដែរ។ បុរសម្នាក់ដែលរស់នៅ ដោយការចុះចូលទាំងស្រុងទៅចំពោះព្រះគ្រិស្ត នឹងបានដឹងពីរបៀបដឹកនាំកិច្ចការនៅក្នុងគ្រួសាររបស់គាត់ តាមរបៀបដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ។ របៀបដឹកនាំនេះរួមបញ្ចូលទាំងការដឹកនាំនៅក្នុងបញ្ហាខាងឯវិញ្ញាណផងដែរ៖ "រីឯខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំវិញ យើងនឹងគោរពបំរើព្រះអម្ចាស់" (គម្ពីរយ៉ូស្វេ ២៤:១៥) ។ (សូមមើលនៅក្នុងគម្ពីរកិច្ចការ ១៦:៣១ ផងដែរ)។ ប្រពន្ធ និង កូនរបស់គាត់ដែលជាគ្រិស្តបរិស័ទ ហើយចុះចូលជាមួយនឹងព្រះអម្ចាស់តែមួយ នឹងចិត្តគាំទ្រ សិទ្ធិអំណាចរបស់គាត់។

ផ្តល់ការផ្គត់ផ្គង់

ប្តីមានទំនួលខុសត្រូវក្នុងការផ្គត់ផ្គង់ តម្រូវការខាងសាច់ឈាមសម្រាប់គ្រួសារ និង ផ្តល់ការការពារសម្រាប់ពួកគេផងដែរ (គម្ពីរ ១ធីម៉ូថេ ៥:៨)។

ផ្តល់ក្តីស្រឡាញ់

ប្តីគឺត្រូវតែស្រឡាញ់ប្រពន្ធរបស់គាត់ *ដូចជាព្រះគ្រិស្តស្រឡាញ់ក្រុមជំនុំ* ដែរ (គម្ពីរអេភេសូ ៥:២៥)។ តើព្រះយេស៊ូស្រឡាញ់ក្រុមជំនុំយ៉ាងដូចម្តេច? ហេតុអ្វី?

១. គាត់ត្រូវលះបង់ខ្លួនឯងដើម្បីនាង (គម្ពីរអេភេសូ ៥:២៥; គម្ពីររ៉ូម៥:៨)។ នេះគឺជាក្តីស្រឡាញ់ដែល មានការបូជារបស់ប្តី ដែលគាត់សុខចិត្តរងទុក្ខដើម្បីប្រពន្ធរបស់គាត់បានទទួលការល្អ។

២. ប្រោសអោយក្រុមជំនុំបានទៅជាវិសុទ្ធ (គម្ពីរអេភេសូ ៥:២៦)។ ក្តីស្រឡាញ់ប្តីគួរតែជា ការលើកទឹកចិត្ត និង ការជម្រុញចិត្ត សម្រាប់ប្រពន្ធរបស់គាត់នៅក្នុងដំណើរខាងវិញ្ញាណរបស់នាងនៅក្នុងព្រះគ្រិស្ត។

៣. ជំរះនាងអោយបានស្អាតបរិសុទ្ធ ដោយលាងក្នុងទឹក និងដោយសារព្រះបន្ទូល (គម្ពីរអេភេសូ ៥:២៦)។ ក្តីស្រឡាញ់របស់ប្តី គួរតែរួមបញ្ចូលទាំងការចែកចាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាមួយប្រពន្ធរបស់គាត់ ដែលអាចឲ្យអ្នកទាំងពីរបានសំអាតឲ្យបរិសុទ្ធ និង អប់រំតាមរយៈព្រះ បន្ទូលនោះផង។

៤. "នាំក្រុមជំនុំ (ភរិយា) នេះមកថ្វាយព្រះអង្គ(ប្តី)ផ្ទាល់ ....អោយបានទៅជាវិសុទ្ធ* ឥតសៅហ្មង។" (គម្ពីរអេភេសូ ៥:២៧)។ ក្តីស្រឡាញ់ដែលមានគោលដៅចង់បានផលប្រយោជន៍សម្រាប់ វិញ្ញាណរបស់ប្រពន្ធ នឹងឆ្លុះបញ្ចាំងឲ្យឃើញពីប្តី តាមរយៈវិញ្ញាណដែលឥតសៅហ្មងរបស់ ប្រពន្ធ។

៥. ព្រះគ្រិស្តស្រឡាញ់យើង*ជាមុន* (គម្ពីរ១យ៉ូហាន ៤:១៩)។ ប្តីគួរតែជាអ្នកបង្ហាញក្តីស្រឡាញ់មុនដំបូងបង្អស់។

៦. ដូចជាព្រះកាយរបស់ព្រះអង្គ (គម្ពីរអេភេសូ ៥:២៩) ។ ក្រុមជំនុំគឺជាព្រះកាយរបស់ព្រះគ្រិស្ត (គម្ពីររ៉ូម១២:៥)។ ការបង្ហាញក្តីស្រឡាញ់បែបនេះ រួមបញ្ចូលទាំងអ្វីៗដែលបុរសម្នាក់ធ្វើសម្រាប់ រូបកាយរបស់គាត់ ក្តីស្រឡាញ់ដែលធ្វើឲ្យគាត់ថែទាំ និង ផ្គត់ផ្គង់សម្រាប់ប្រពន្ធរបស់គាត់តាមគ្រប់មធ្យោបាយ។ ក្តីស្រឡាញ់នេះ គឺផ្តល់ទៅតាមរយៈភាពស្មោះត្រង់របស់គាត់ទៅចំពោះនាង (គម្ពីរសុភាសិត ៥:១៥,១៨,១៩; គម្ពីរម៉ាឡាគី ២:១៥-១៦) តាមរយៈការចេះយល់ចិត្ត (គម្ពីរ១ពេត្រុស ៣:៧ គម្ពីរកូឡូស ៣:១៩)និង តាមរយៈការបង្ហាញការកោតសរសើរ (គម្ពីរសុភាសិត ៣១:២៨-៣១)។

លំហាត់អនុវត្តន៍

១៤ តើអ្នកគិតថាហេតុអ្វីបានជាវាមានសារៈសំខាន់យ៉ាងខ្លាំង ដែលប្តីត្រូវស្រឡាញ់ប្រពន្ធរបស់គាត់ នៅក្នុងរបៀបទាំងនេះ?

....

....

ទំនួលខុសត្រូវរបស់ប្រពន្ធ

នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី មិនបានបង្រៀនថា ស្ត្រីគឺតូចទាបជាងបុរសនោះឡើយ៖ "...គ្មានបុរស គ្មានស្ត្រីទៀតដែរ គឺបងប្អូនទាំងអស់បានរួមគ្នាមកជាអង្គតែមួយ ក្នុងព្រះគ្រិស្តយេស៊ូ" (គម្ពីរកាឡាទី ៣:២៨)។ បទគម្ពីរនោះក៏បានលើកឡើងអំពី ទាសករ អ្នកមានសេរីភាព សាសន៍យូដា និង សាសន៍ក្រិកផងដែរ។ បទគម្ពីរនេះបានបង្រៀនថា ព្រះគ្រិស្តទទួលមនុស្សទាំងអស់ ឲ្យពួកគេមានកម្រិតស្មើៗគ្នា មិនថាគេមានភាពខុសគ្នាយ៉ាងណាក៏ដោយ។ ភាពជាអ្នកដឹកនាំរបស់ប្តី គឺរឿងដែលទាក់ទងទៅនឹងការទទួលខុសត្រូវ និង ការរៀបចំឲ្យមានរចនាសម្ព័ន្ធដែលមានឋានានុក្រមត្រឹមត្រូវ។ សហគមន៍គ្រប់ទាំងអស់ត្រូវមានការដឹកនាំ ហើយព្រះជាម្ចាស់បានជ្រើសរើសស្វាមីដើម្បីឲ្យធ្វើជាអ្នកដឹកនាំនៅក្នុងគ្រួសារ។

ដើម្បីឲ្យមានអ្នកដឹកនាំមួយបាន ត្រូវតែមានអ្នកដើរតាម។ ប្រពន្ធធ្វើតាមការដឹកនាំរបស់ប្តីនាងដោយការចុះចូលរបស់នាង ៖ "ហេតុនេះ ក្រុមជំនុំគោរពចុះចូលនឹងព្រះគ្រិស្តយ៉ាងណា ភរិយាក៏ត្រូវគោរពចុះចូលនឹងស្វាមីរៀងៗខ្លួន ក្នុងគ្រប់កិច្ចការទាំងអស់យ៉ាងនោះដែរ។" (គម្ពីរអេភេសូ ៥:២៤) ។ ការចុះចូលរបស់ប្រពន្ធ គឺត្រូវធ្វើឲ្យដូចជាការ *ចុះចូលនឹងព្រះជាម្ចាស់* (ជំពូក៥:២២) *ដោយការគោរព* (ជំពូក ៥:៣៣) ហើយ*ស្របតាមរបៀបអ្នកជឿលើព្រះអម្ចាស់* (គម្ពីរកូឡូស ៣:១៨)។ សូមពិចារណាពីការនេះបន្តិច! ការប្តេជ្ញា និង ការចុះចូល ដូចគ្នានឹងទង្វើរបស់យើងទៅកាន់ព្រះជាម្ចាស់ ក៏ត្រូវតែជាទង្វើរបស់អ្នកទៅចំពោះស្វាមីរបស់អ្នកដែរ។ ប្រពន្ធដែលជាគ្រិស្តបរិស័ទម្នាក់ នឹងលើកប្តីរបស់នាងឲ្យបានខ្ពង់ខ្ពស់ នាងនឹងតម្កើងគាត់ ពេញចិត្តនឹងគាត់ និងអ្វីដែលគាត់ធ្វើ ជាងមនុស្សអ្នកដទៃ ព្រមទាំង សរសើរគាត់ផងដែរ។ ហើយប្រសិនបើស្វាមីរបស់នាងមិនមែនជាអ្នកជឿនោះទេ នាងអាចយកឈ្នះគាត់បានដោយសារតែអាកប្បកិរិយារបស់នាង ដែលមិនចាំបាច់*និយាយ*អ្វីនោះទេ (គម្ពីរ ១ពេត្រុស ៣:១)។ នេះមានន័យថា របៀបរស់នៅដែលយោងទៅតាមគោលការណ៍របស់គ្រិស្តបរិស័ទ នឹងអាចឈ្នះ បានចិត្តប្តីដែល មិនមែនជាអ្នកជឿដោយមិនចាំបាច់ត្រូវតែនិយាយអ្វីឡើយ។

គម្ពីរទីតុស ២:៣-៥ បានផ្តល់ឲ្យយើងនូវទំនួលខុសត្រូវផ្សេងទៀតរបស់ប្រពន្ធ។ រឿងទាំងនេះគឺជាអ្វីដែលស្ត្រីៗចំណាស់ ត្រូវតែបង្រៀនទៅកាន់ស្ត្រីៗវ័យក្មេង ប៉ុន្តែស្ត្រីៗវ័យចំណាស់ ត្រូវតែប្រាកដថាជីវិតរបស់ពួកគាត់គឺជាគំរូមួយផងដែរ។ ពួកគាត់ត្រូវតែមានរបៀបរស់នៅដ៏គួរឲ្យគោរព មិនមែនជាអ្នកនិយាយមួលបង្កាច់គេ និងមិនមែនជាអ្នកចំណូលស្រានោះទេ ។ បន្ទាប់មក ពួកគាត់អាចបង្រៀនពួកប្រពន្ធដែលនៅក្មេងបានហើយ។

លំហាត់អនុវត្តន៍

១៥ សូមអានគម្ពីរទីតុស ២:៣-៥ ហើយសរសេររៀបរាប់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក នូវការល្អប្រាំពីរ យ៉ាងដែលស្ត្រីចាស់ៗ ត្រូវតែបង្រៀនស្ត្រីៗនៅក្មេង?

ទំនួលខុសត្រូវរបស់ឪពុកម្តាយ

ឪពុកម្តាយមានទំនួលខុសត្រូវបណ្តុះបណ្តាលកូនៗរបស់ពួកគេៗ

ការបណ្តុះបណ្តាលត្រូវមានគ្រប់មធ្យោបាយ ទាំងការបង្ហាញ*គំរូ ការបង្រៀន* និង *ការប្រៀនប្រដៅ* នៅពេលណាដែលត្រូវការ។ កូនៗ រៀនសូត្រតាមអ្វីដែលគេមើលឃើញនៅក្នុងមជ្ឈដ្ឋានជុំវិញរបស់ពួកគេ។ ពួកគេក៏រៀនសូត្រដោយទទួលការបង្ហាត់បង្រៀន និង ពេលខ្លះពួកគេរៀនសូត្របានដោយទទួលការប្រៀនប្រដៅ ដោយមានរបៀបវិន័យសមរម្យ។ (គម្ពីរសុភាសិត ២៩:១៥,១៧)។ (សូមមើលនៅក្នុងគម្ពីរសុភាសិត ២២:៦ និង គម្ពីរអេភសូ ៦:៤ ផងដែរ។)

ការប្រៀនប្រដៅកូនៗ ត្រូវតែយុត្តិធម៌

"រីឯបងប្អូនដែលជាឪពុកវិញ កុំធ្វើអោយកូនរបស់ខ្លួនមួម៉ៅនោះឡើយ" (គម្ពីរអេភេសូ ៦:៤)។ "បងប្អូនដែលមានកូនអើយ កុំដុកដាន់កូនរបស់ខ្លួនឡើយ ក្រែងលោវាបាក់ទឹកចិត្ត។" (គម្ពីរកូឡុស ៣:២១)។ មិនត្រូវប្រៀនប្រដៅលើកូនដោយសារតែអ្វី ដែលពួកគេមិនដឹងថាជារឿងដែលខុសនោះទេ ហើយក៏មិនត្រូវប្រៀនប្រដៅពួកគេដោយសារតែកំហឹងរបស់អ្នកដែរ។ ការប្រៀនប្រដៅត្រូវធ្វើដោយមានការទប់ចិត្ត។ កូនៗត្រូវតែដឹងថា នឹងមានផលវិបាកដោយសារសកម្មភាពមួយចំនួន។ នេះមានន័យថា ឪពុកម្តាយត្រូវចំណាយពេលវេលា និង កម្លាំងដែលចាំបាច់សម្រាប់ប្រៀនប្រដៅកូនៗនៅពេលណាដែលពួកគេត្រូវការការប្រៀនប្រដៅតែប៉ុណ្ណោះ ។ ចូរបកស្រាយពីមូលហេតុដែលពួកគេត្រូវទទួលការប្រៀនប្រដៅហើយអ្នកអាចអធិស្ឋានជាមួយគេអំពីការនោះផងដែរ។ (គម្ពីរហេព្រើ ១២:៦-៩; គម្ពីរ ២ធីម៉ូថេ ៣:១៦-១៧)

ការប្រៀនប្រដៅកូនៗគឺមានន័យដូចជាជីវិតសម្រាប់ពួកគេយ៉ាងដូច្នោះដែរ។ កូនៗមិនអាចនាំខ្លួនគេចូលទៅក្រោមសិទ្ធិអំណាចរបស់ព្រះជាម្ចាស់បានទេ ប្រសិនបើពួកគេមិនធ្លាប់បានរៀនសូត្រពីការនាំខ្លួនគេឲ្យចូលទៅក្រោមសិទ្ធិអំណាចរបស់ឪពុកម្តាយរបស់ពួកគេផងនោះ។ (សូមមើលគម្ពីរសុភាសិត ១៩:១៨; ២៣:១៣-១៤; ២៩:១៧)

ការបណ្តុះបណ្តាល និង ការប្រៀនប្រដៅ ត្រូវធ្វើប្រកបដោយក្តីស្រឡាញ់

ឪពុកម្តាយត្រូវតែកែប្រែឥរិយាបថរបស់ពួកគេ ទៅតាមព្រះវរបិតានៃស្ថានបរមសុខ៖ "ទោះបីព្រះអង្គដាក់ទោសក្តី ព្រះអង្គនៅតែអាណិតមេត្តាដដែល ដ្បិតព្រះហឫទ័យសប្បុរសរបស់ព្រះអង្គ ធំពន់ពេកក្រៃ។ ព្រះអង្គមិនសប្បាយព្រះហឫទ័យនឹង ដាក់ទោស ឬធ្វើទណ្ឌកម្មមនុស្សម្នាទេ។" (គម្ពីរបរិទេវ ៣:៣២-៣៣)។

លំហាត់អនុវត្តន៍

១៦ សូមអានគម្ពីរហេប្រឺ ១២:៥-១១ ហើយគូសរង្វង់ជុំវិញ អក្សរនៅពីមុខចម្លើយត្រឹមត្រូវដែលបក

ស្រាយអំពីមូលហេតុដែលព្រះជាម្ចាស់ប្រៀនប្រដៅ កូនចៅរបស់ទ្រង់ និងមូលហេតុដែល ឪពុក ម្តាយត្រូវប្រៀនប្រដៅកូនៗរបស់ពួកគេ។

ក) ទ្រង់សព្វព្រះទ័យក្នុងការស្តីបន្ទោសកូនចៅរបស់ទ្រង់។

ខ) ទ្រង់ស្រឡាញ់កូនចៅរបស់ទ្រង់។

គ) ពួកគេជាកូនចៅរបស់ទ្រង់។ (ទ្រង់មានទំនួលខុសត្រូវចំពោះពួកគេ)។

ឃ) ទ្រង់ក្រោធចំពោះពួកគេ ហើយចង់ដាក់ទោសពួកគេ។

ង) ដើម្បីទទួលបានការគោរពរបស់ពួកគេ។

ច) ដើម្បីឲ្យពួកគេបានល្អ ដែលពួកគេអាចទទួលបានភាពវិសុទ្ធរបស់ទ្រង់។

ឆ) ដើម្បីធ្វើឲ្យពួកគេឈឺចាប់។

ជ) ដើម្បីធ្វើឲ្យមានភាពសុចរិត និង សន្តិភាព។

យើងបានឃើញនៅក្នុងបទគម្ពីរនេះរួចមកហើយថា ការឆ្លើយតបរបស់កូនទៅចំពោះការប្រៀនប្រដៅរបស់ឪពុកម្តាយគេ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងជីវិតរបស់គេទៅថ្ងៃមុខ ក្នុងការចុះចូលទៅចំពោះព្រះជាម្ចាស់ និង ការប្រៀនប្រដៅរបស់ទ្រង់។

ទំនួលខុសត្រូវរបស់កូនៗ

ដំបូងបង្អស់ កូនៗតម្រូវឲ្យគោរព និង ស្តាប់បង្គាប់ឪពុកម្តាយរបស់ពួកគេ (គម្ពីរនិក្ខមនំ ២០:១២; គម្ពីរអេភេសូ ៦:១-៣)។ ព្រះពររបស់ព្រះជាម្ចាស់ គឺស្ថិតនៅជាមួយកូនៗណាដែលស្តាប់បង្គាប់ឪពុកម្តាយរបស់ពួកគេ (គម្ពីរយេរេមា ៣៥:៦-៧,១៨-១៩)។ កូនៗណាដែលស្តាប់បង្គាប់ឪពុកម្តាយរបស់ពួកគេបានច្រើន នោះពួកគេមុខជាអាចបណ្តុះបណ្តាលកូនៗរបស់ពួកគេបានល្អផងដែរ។

ការគោរពឪពុកម្តាយរបស់អ្នក មិនមែនត្រូវបានបញ្ចប់នៅពេលដែលអ្នកបានធំពេញវ័យនោះទេ។ យុវជនវ័យក្មេងម្នាក់ត្រូវតែចងចាំការណែនាំ និង ការបង្ហាត់បង្រៀនរបស់ឪពុក ឬម្តាយរបស់គាត់ នៅពេលដែលគាត់ចាកចេញទៅ ក្នុងពិភពលោកដោយខ្លួនឯង។ យុវជនយុវនារី ដែលទទួលបានផលចំណេញពីការបង្រៀនរបស់ឪពុកម្តាយគេ នោះនឹងនាំឲ្យពួកគេមានអំណរយ៉ាងអស្ចារ្យ។ (គម្ពីរសុភាសិត ២៣:២២-២៥)

នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ មានការដាក់ទោសយ៉ាងធ្ងន់ធ្ងរទៅលើកូនៗណា ដែលមិនស្តាប់បង្គាប់ និង មិនចេះគោរព (សូមមើលគម្ពីរនិក្ខមនំ ២១:១៥ ; គម្ពីរលេវីវិន័យ ២០:៩; គម្ពីរទុតិយកថា ២១:១៨-២១; គម្ពីរសុភាសិត ២៨:២៤; ៣០:១៧)។

លំហាត់អនុវត្តន៍

១៧ ចូរសរសេរ ឋានៈនៅក្នុងសមាជិកគ្រួសារនីមួយៗ ហើយសរសេរទំនួលខុសត្រូវចម្បងសម្រាប់សមាជិកនីមួយៗក្នុងគ្រួសារ ដាក់ក្នុងតារាងខាងក្រោមនេះ។

ព្រះគ្រិស្តជា សិរសារបស់គ្រួសារ	
ឋានៈ	**ទំនួលខុសត្រូវចម្បង**
ក)	
ខ)	
គ)	

នៅពេលដែលមានការព្រងើយកន្តើយចំពោះ សេចក្តីណែនាំដ៏វិសុទ្ធទាក់ទងនឹងទំនួលខុសត្រូវរបស់សមាជិកគ្រួសារទាំងនេះ នោះមុខជាមានបញ្ហាកើតមានឡើងជាមិនខាន។ គំរូរបស់ព្រះជាម្ចាស់គឺពិតជាមានប្រសិទ្ធិភាព ហើយគ្រួសារដែលរស់នៅតាមគោលការណ៍ទាំងនេះ នឹងបានស្គាល់ពីក្តីស្រឡាញ់ ភាពរីករាយ និង ភាពពេញបរិបូរណ៌។ តើនេះគឺជាប្រភេទនៃគ្រួសាររបស់អ្នកមែនទេ? ប្រសិនបើមិនមែននោះទេ តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីឲ្យគ្រួសាររបស់យើងក្លាយទៅជា គ្រួសារដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ? អ្នកអាចចាប់ផ្តើមពីខ្លួនឯងទៅ នៅពេលដែលអ្នកបំពេញទំនួលខុសត្រូវដែលព្រះជាម្ចាស់បានប្រទានឲ្យអ្នកទៅចំពោះគ្រួសាររបស់អ្នកហើយ នោះវានឹងមានភាពងាយស្រួលដើម្បីឲ្យសមាជិកគ្រួសារផ្សេងទៀតដើរតាមជំហានដូចគ្នានោះដែរ។ ការធ្វើការផ្លាស់ប្តូរមួយ ប្រហែលជាមិនងាយស្រួល ឬ បានឆាប់ៗនោះទេ ប៉ុន្តែលទ្ធផលដែលនឹងទទួលបាន គឺពិតជាស័ក្តិសមគួរឲ្យធ្វើណាស់!

លំហាត់អនុវត្តន៍

១៨ ដូចដែលយើងបានធ្វើនៅក្នុងមេរៀនមុនដែរ យើងខ្ញុំសូមលើកទឹកចិត្តអ្នកក្នុងពេលនេះ ឲ្យយកគោលការណ៍នៃមេរៀននេះទៅអនុវត្ត ដើម្បីស្វែងរកដំណោះស្រាយសម្រាប់បញ្ហាដែលអាចមាននៅក្នុងគ្រួសាររបស់អ្នក។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាជំនួយដ៏បរិបូរណ៌ហូរហៀរ។ ចូរអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជុំគ្នាក្នុងគ្រួសារ ហើយអនុញ្ញាតឲ្យទ្រង់មានព្រះបន្ទូលមកកាន់ដួងចិត្តរបស់អ្នក។

ការប្រឡងផ្ទាល់ខ្លួន

សំណួរពហុជម្រើស៖ ចូរជ្រើសរើសចម្លើយដែលល្អបំផុតសម្រាប់សំណួរនីមួយៗ។

១ ឋានៈរបស់ប្ដីចំពោះប្រពន្ធរបស់គាត់អាចប្រៀបធៀបទៅនឹងឋានៈរបស់

ក) ម្ដាយចំពោះកូនរបស់គាត់។

ខ) ក្រុមជំនុំទៅចំពោះព្រះគ្រិស្ដ។

គ) ព្រះគ្រិស្ដទៅចំពោះក្រុមជំនុំ។

២ ការបណ្ដុះបណ្ដាលកូនៗដែលត្រឹមត្រូវ មានរួមបញ្ចូល

ក) ការដាក់ទោស និង ការព្រមព្រៀង

ខ) ការបង្រៀន ការប្រៀនប្រដៅ និង ក្ដីស្រឡាញ់

គ) ការបណ្ដោតបណ្ដោយ

ឃ) ការទិទៀនរិះគន់

៣ ការលែងលះ ត្រូវបានអនុញ្ញាតឲ្យធ្វើបានតែនៅក្នុងករណី

ក) អំពើសហាយស្មន់

ខ) ការរៀបការជាមួយអ្នកមិនជឿ

គ) មានការមិនចុះសម្រុងគ្នា ទៅលើរឿងកូនៗ

ឃ) មានការប្រច័ណ្ឌ

៤ ជនរងគ្រោះខ្លាំងបំផុតនៅក្នុង ការលែងលះគ្នាគឺ

ក) ប្ដី

ខ) ប្រពន្ធ

គ) ភាគីដែលត្រូវបានគេបំពាន

ឃ) កូនៗ

៥ ប្រសិនបើអ្នកដែលបានលែងលះប្ដីប្រពន្ធ រៀបការម្ដងទៀតនៅមុនពេលដែលគាត់ប្រែចិត្តទទួលជឿ នោះក្រោយពេលដែលបានផ្លាស់ប្រែហើយ

ក) ត្រូវត្រឡប់ទៅរកអាពាហ៍ពិពាហ៍ចាស់របស់គាត់។

ខ) បញ្ចប់អាពាហ៍ពិពាហ៍ទីពីររបស់គាត់ ហើយទៅរស់នៅតែម្នាក់ឯង។

គ) បន្តរស់នៅជីវិតអាពាហ៍ពិពាហ៍ថ្មី ក្នុងពេលដែលបានធ្វើការផ្លាស់ប្រែនោះ។

៦ តើមានអ្វីដែលបានបាត់បង់ក្នុងចំណងអាពាហ៍ពិពាហ៍មួយ នៅពេលដែលដៃគូម្ខាងបន្ថោក (មើលងាយ)តម្លៃ របស់ដៃគូម្ខាងទៀត?

ក) ភាពជាអ្នកដឹកនាំ

ខ) ក្តីស្រឡាញ់ និង ការគោរព

គ) ទំនុកចិត្ត

ឃ) ការរួបរួម

៧ បញ្ហាហិរញ្ញវត្ថុនៅក្នុងគ្រួសារមួយ អាចដោះស្រាយបានយ៉ាងងាយ នៅពេលដែលប្តីប្រពន្ធមានការយល់ព្រម

ក) ធ្វើការជាច្រើនម៉ោងថែមទៀត។

ខ) ទុកឲ្យប្រពន្ធជាអ្នកចាត់ចែងលុយកាក់។

គ) ថ្វាយដង្វាយរបស់គេជាមុនសិន។

ឃ) ជៀសវាងការចំណាយដែលមិនបានព្រៀងទុក។

ត្រូវ/ខុស។ ចូរសរសេរអក្សរ **ត** នៅមុខចម្លើយត្រឹមត្រូវ និង សរសេរអក្សរ **ខ** នៅមុខចម្លើយដែលមិនត្រឹមត្រូវ។

.........៨ ម្តាយគួរតែជាអ្នកដឹកនាំខាងឯវិញ្ញាណនៅក្នុងគ្រួសារ។

.........៩ ការប្តេជ្ញាជ្រុលនៅលើសកម្មភាពដែលនៅខាងក្រៅផ្ទះ គឺជាបញ្ហានៅពេលណាដែលវារារាំងមិនឲ្យគ្រួសារបានចំណាយពេលជាមួយគ្នា។

.........១០ កូនៗដែលស្តាប់បង្គាប់ ភាគច្រើនអាចបម្រើព្រះជាម្ចាស់ ជាជាងកូនដែលមិនស្តាប់បង្គាប់។

.........១១ គ្រិស្តបរិស័ទដែលរៀបការជាមួយអ្នកមិនជឿ គឺអាចមានសេរីដើរចេញពេលណាក៏បាន។

.........១២ អាទិភាពទីមួយរបស់បុរសម្នាក់ គឺទៅចំពោះឪពុកម្តាយរបស់គាត់។

.........១៣ ឪពុកម្តាយគួរត្រៀមខ្លួនជានិច្ចដើម្បីជួយកូនណាដែលបានបះបោរ។

.........១៤ ទំនួលខុសត្រូវរបស់ប្តី គឺត្រូវដឹកនាំគ្រួសាររបស់គាត់ និង ធ្វើការផ្គត់ផ្គង់ពួកគេ។

.........១៥ ភាពជាប្រមុខរបស់គ្រួសារត្រូវបង្កើតឡើងដោយក្តីស្រឡាញ់ ដើម្បីជាប្រយោជន៍ឲ្យវាអាចដំណើរការទៅបានយ៉ាងរលូន។

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១០ អ្នកដឹកនាំត្រូវចេះមើលការខុសត្រូវ ក្រុមគ្រួសារ និង ផ្ទះសម្បែងរបស់ពួកគេ ហើយឃើញថាកូនៗរបស់ពួកគេចេះស្តាប់បង្គាប់ និង គោរពពួកគេផងដែរ។ (ខ៤ ,ខ៥ និង ខ១២)។

១ ខ) វាមិនអាចមានការព្រមព្រៀងបាននោះទេ រវាងរឿងទាំងនេះ ព្រោះរឿងនីមួយៗមានគុណតម្លៃផ្ទុយគ្នា។

១១ ខ) ប្រពន្ធ និង កូន (លើកលែងតែមានតម្រូវការរបស់ឪពុកម្តាយ ដែលប្រពន្ធក៏យល់ស្របថាជាអាទិភាពចម្បងដែរ។

២ ព្រោះពួកគេគឺជារូបកាយតែមួយរួចទៅហើយ នោះគឺជាការប្តេជ្ញាចិត្តអស់មួយជីវិត។

១២ ក) ៣) បញ្ហាហិរញ្ញវត្ថុ

ខ) ៤) កង្វះការគោរព

គ) ៧) ការប្រច័ណ្ឌ

ឃ) ១) ការប្តេជ្ញាជ្រុល

ង) ៥) ភាពខុសគ្នាក្នុងការបណ្តុះបណ្តាលកូន

ច) ២) បញ្ហាទាក់ទងនឹងសាច់ញាត្តិ

ឆ) ៦) កង្វះទំនាក់ទំនង

៣ ក) គ្រិស្តបរិស័ទគួរតែរៀបការជាមួយអ្នកណាដែលជាគ្រិស្តដូចគ្នាប៉ុណ្ណោះ។

ខ) ប្តីគួរតែជាអ្នកដឹកនាំខាងឯវិញ្ញាណនៅក្នុងគ្រួសារ។

១៣ ក) ឪពុកម្តាយមិនគួរអនុញ្ញាតឲ្យមានការមិនស្តាប់បង្គាប់ទេ ប៉ុន្តែគួរតែយកចិត្តទុកដាក់បណ្តុះបណ្តាលកូនៗរបស់ពួកគេ និង បង្ហាញថាអ្នកស្រឡាញ់ពួកគេ ។

៤ ខ) មានបំណងចង់បំពេញឲ្យគ្នាទៅវិញទៅមក។

១៤ ចម្លើយរបស់អ្នក។ សម្រាប់ខ្ញុំ ខ្ញុំអាចឆ្លើយយ៉ាងដូច្នេះ៖ ប្តីទទួលបានតំណែងជាប្រមុខដឹកនាំលើប្រពន្ធរបស់គាត់។ មធ្យោបាយមួយគត់ដែលគាត់អាចបំពេញទំនួលខុសត្រូវនេះបានល្អ គឺមានជាមួយនឹងក្តី*ស្រឡាញ់* ។

៥ គ) ដៃគូប្តីប្រពន្ធ មានសេរីភាពអាចចាកចេញ ប្រសិនបើដៃគូម្ខាងទៀតបានប្រព្រឹត្តបាបក្នុងអំពើសហាយស្មន់។

ឃ) បាបនៃអំពើសហាយស្មន់ អាចនឹងត្រូវបានអត់ទោសឲ្យ ហើយចំណងអាពាហ៍ពិពាហ៍អាចបន្តសាជាថ្មី។

១៥ ស្ត្រីគ្រប់រូបត្រូវចេះស្រឡាញ់ស្វាមី ស្រឡាញ់កូនរបស់ខ្លួន អោយមានចិត្តធូន់ មានចរិយាបរិសុទ្ធយកចិត្តទុកដាក់នឹងកិច្ចការក្នុងផ្ទះសំបែង មានចិត្តល្អ និងគោរពចុះចូលនឹងស្វាមីរៀងៗខ្លួន។

៦ ខ) ដៃគូដែលរងគ្រោះ អាចលែងលះ និង រៀបការម្តងទៀតបាន។

១៦ ខ), គ), ង), ច) និង ជ) ជាចម្លើយត្រឹមត្រូវ។

៧ ដែគូប្តីប្រពន្ធនេះ គួរតែបន្តរស់នៅក្នុងស្ថានភាពដែលពួកគេទទួលបានការប្រោសលោះ នោះមានន័យថា ពួកគេគួរបន្តជីវិតអាពាហ៍ជាមួយគ្នា និងទទួលយកភាពតែមួយដែលព្រះជាម្ចាស់បានប្រទានឲ្យពួកគេតាមរយៈការលន់តួ និងការកើតជាថ្មីនៅក្នុងព្រះគ្រិស្ត។

១៧ ក) ប្តី ត្រូវដឹកនាំ ផ្គត់ផ្គង់ ស្រឡាញ់ប្រពន្ធកូន និង បណ្តុះបណ្តាលកូនៗផងដែរ។

ខ) ប្រពន្ធ ត្រូវចុះចូលជាមួយការដឹកនាំរបស់ប្តី ថៃទាំផ្ទះសម្បែង ស្រឡាញ់ប្តីនិងកូន និង ជួយបណ្តុះបណ្តាលកូនផងដែរ។

គ) កូនៗ ត្រូវស្តាប់បង្គាប់ និង គោរពឪពុកម្តាយ។

៨ គ្រិស្តបរិស័ទ គឺត្រូវបានហាមផ្តាច់មិនឲ្យលែងលះគ្នា។ គ្រិស្តបរិស័ទមិនអាចរៀបការជាមួយអ្នកដែលបានលែងលះគ្នានោះទេ។ អ្នកដែលបានលែងលះមិនអាចការម្តងទៀតបានឡើយ។

១៨ ចម្លើយរបស់អ្នក

៩ ឃ) ការទុកចិត្ត